ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# «ប្រសិទ្ធភាព នៃការធ្វើកំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨»

## ករណីសិក្សា៖ ខេត្តកំពត

"The Effectiveness of the Upper Secondary Exams Reform

From 2017-2018"

Case Study: Kampot Province


ដោយ/BY

**ពុត ពិសី**

PUTH PISEY


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា៖ ២០១៧-២០១៩


ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation (CIESF)

# ក្រសួងអប់រំ យុវជន និងកីឡា

**Ministry of Education, Youth and Sport**


## វិទ្យាស្ថានជាតិអប់រំ

**National Institute of Education**


# និក្ខេបបទ

# «ប្រសិទ្ធភាព នៃការធ្វើកំណែទម្រង់ការប្រឡងមធ្យមសិក្សា ទុតិយភូមិពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨»

## ករណីសិក្សា៖ ខេត្តកំពត

"The Effectiveness of the Upper Secondary Exams Reform From 2017-2018"

Case Study: Kampot Province


ដោយ/BY

**ពុត ពិសី**

PUTH PISEY


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា៖ ២០១៧-២០១៩


**សាស្ត្រាចារ្យដឹកនាំ៖ បណ្ឌិត នី រដ្ឋា**

**សាស្ត្រាចារ្យដឹកនាំរង៖ លោកស្រី នូ ចន្ទី**



ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

## «ប្រសិទ្ធភាព នៃការធ្វើកំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨»

## ករណីសិក្សា៖ ខេត្តកំពត

"The Effectiveness of the Upper Secondary Exams Reform
From 2017-2018"

Case Study: Kampot Province

ដោយ/BY

**ពុត ពិសី**

PUTH PISEY

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា៖ ២០១៧-២០១៩

សាស្ត្រាចារ្យដឹកនាំ៖ បណ្ឌិត នី រដ្ឋា
សាស្ត្រាចារ្យដឹកនាំរង៖ លោកស្រី នូ ចន្ទី

ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា
Supported by Cambodia International Education Support Foundation ( CIESF )

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៩៦២៩ **អយក.** ទស

(**ការសម្រាត់**)

# លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុធន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទធាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- -អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
- -គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- -សាមីខ្លួន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ - ឯកសារៈវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# **សេចក្តីប្រកាសអះអាងរបស់បេក្ខជន**

ខ្ញុំបាទសូមអះអាងថា និក្ខេបបទដែលមានចំណងជើងថា **«ប្រសិទ្ធភាព នៃការធ្វើកំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិទុតិយភូមិ ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨»** សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំនេះ គឺជាស្នាដៃសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទពិតប្រាកដមែន។ ហើយស្នាដៃនេះមិនដែលបានប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាន ឬសាកលវិទ្យាល័យណាមួយឡើយ ។ បន្ថែមលើសពីនេះទៅទៀត រាល់សេចក្តីដកស្រង់និងខ្លឹមសារផ្សេងៗ ដែលបានយកមកប្រើប្រាស់នៅក្នុងអត្ថបទនេះ សុទ្ធតែបានចុះបញ្ជីក្នុងឯកសារយោងទាំងអស់។ និក្ខេបបទសិក្សាស្រាវជ្រាវខាងលើពិតជាត្រូវបានសិក្សា និងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

**ហត្ថលេខាបេក្ខជន**

**ពុត ពិសី**

# លិខិតបញ្ជាក់

**បណ្ឌិត** **នី រដ្ឋា** ជាសាស្ត្រាចារ្យដឹកនាំ

**លោកស្រី** **នូ ចន្នី** ជាសាស្ត្រាចារ្យដឹកនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ពុត ពិសី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបាន សរសេរនិក្ខេបបទស្រាវជ្រាវ «**ប្រសិទ្ធភាព នៃការធ្វើកំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិ ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨**»ពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

.......................................        .....................................

| | |
|---|---|
| **បណ្ឌិត នី រដ្ឋា** | **លោកស្រី នូ ចន្នី** |
| ប្រធានការិយាល័យសិក្សា វិទ្យាស្ថានជាតិអប់រំ | សាស្ត្រាចារ្យឧទ្ទេស វិទ្យាស្ថានជាតិអប់រំ |

## **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា Cambodia International Education Support Foundation(CIESF) ដែលបានរៀបចំកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់ណែនាំគ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការនឿយហត់ឡើយ។ ជាពិសេសខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់លោក **បណ្ឌិត នី រដ្ឋា** ដែលតែងតែចំណាយពេលវេលាមកពន្យល់ខ្ញុំបាទគ្រប់ជំហាន និងតែងតែបានលើកទឹកចិត្តគ្រប់ពេលដល់ខ្ញុំបាទ ទើបធ្វើឱ្យការស្រាវជ្រាវរបស់ខ្ញុំនាពេលនេះទទួលបានជោគជ័យ និងភាពរលូន។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមអរគុណដល់លោកស្រីជាសាស្ត្រាចារ្យជំនួយ **នូ ចន្ធី** ដែលបានពន្យល់នូវគន្លឹះសំខាន់ៗមួយចំនួន ក្នុងការស្រាវជ្រាវមួយនេះ រួមទាំងមិត្តរួមជំនាន់ទី៦ទាំងអស់ ដែលតែងតែផ្តល់ជាគំនិតល្អៗ ក៏ដូចជាការងារបច្ចេកទេសកុំព្យូទ័រមួយចំនួន និងផ្តល់ជាកម្លាំងចិត្តតាមរយៈការចែករំលែកនូវ ចំណេះដឹង បទពិសោធន៍ព័ត៌មានទាំងឡាយដល់រូបខ្ញុំបាទ ដើម្បីឱ្យការស្រាវជ្រាវនេះមានភាពងាយស្រួល។

បន្ថែមពីនេះទៀត ខ្ញុំសូមថ្លែងអំណរគុណដល់ **លោកឪពុក អ្នកម្តាយ ភរិយា និងកូនៗ** របស់ខ្ញុំ ដែលបានផ្តល់នូវពេលវេលា ប្រាក់កាស ព្រមទាំងបងប្អូន មិត្តភក្តិទាំងអស់ ដែលតែងតែបានជំរុញ និងលើកទឹកចិត្តដើម្បីឱ្យខ្ញុំបន្តការសិក្សារហូតបានបញ្ចប់នូវ ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ដោយជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធិពរជ័យជូនចំពោះ **ឯកឧត្តមបណ្ឌិត** លោក លោកស្រី ជាសាស្ត្រាចារ្យ មិត្តរួមថ្នាក់ ក្រុមគ្រួសារ និងភរិយា ព្រមទាំងកូនៗខ្ញុំបាទ សូមឱ្យជួបតែនឹងសេចក្តីសុខព្រមទាំងពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។**

**សូមអរគុណ!**

# មូលន័យសង្ខេប

នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនលើសកលលោក តែងតែមានការផ្តោតយកចិត្តទុកដាក់ការធ្វើកំណែទម្រង់លើគ្រប់វិស័យ សំដៅធ្វើយ៉ាងណាឱ្យល្អប្រសើរឡើងនូវធនធានមនុស្ស និងសន្ទុះកំណើនសេដ្ឋកិច្ចជាតិ ពីមួយឆ្នាំទៅមួយឆ្នាំ។ ការលើកកម្ពស់សមត្ថភាព និងជំនាញរបស់មនុស្សត្រូវបានឱ្យតម្លៃជាអាទិភាពស្នូលយ៉ាងសំខាន់ ដើម្បីជម្រុញឱ្យប្រទេសនោះទទួលបានការអភិវឌ្ឍប្រកបដោយចីរភាព។

ក្នុងនាមជាមន្ត្រីអប់រំ និងជាអ្នកស្រាវជ្រាវម្នាក់ សូមចូលរួមធ្វើការសិក្សាស្រាវជ្រាវនិក្ខេបបទមួយស្តីអំពី **“ប្រសិទ្ធភាព នៃការធ្វើកំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិពីឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨”** ដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវ គុណភាពអប់រំ និងដើម្បីពង្រឹងនូវសមត្ថភាពសិស្សក្នុងពេលប្រឡង។ ជាពិសេសទៅទៀតនោះ គឺដើម្បីលុបបំបាត់អំពើពុករលួយផ្សេងៗ នៅក្នុងពេលប្រឡង ហើយក្រសួងអប់រំបានអនុវត្តកម្មវិធីកំណែទម្រង់នេះ ចាប់តាំងពីឆ្នាំ២០១៤ គិតមកដល់ដើមឆ្នាំ២០១៨នេះ ក្រសួងអប់រំអនុវត្តបានចំនួន០៥ឆ្នាំកន្លងមកហើយ ហើយបាននឹងកំពុងបន្តអនុវត្តកម្មវិធីនេះ ជាបន្តទៀត។ ម្យ៉ាងវិញទៀត គឺក្នុងគោលបំណង៖

១). **រកឱ្យឃើញពីយន្តការនានា** ដែលធ្វើឱ្យការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ កាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់ថែមទៀត។

២). **រកឱ្យឃើញពីបញ្ហាប្រឈម និងភាពមិនប្រក្រតីផ្សេងៗ** ក្នុងពេលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ដូចនេះដើម្បីឱ្យសម្រេចបាននូវ គុណភាព និងប្រសិទ្ធភាព តាមរយៈការធ្វើកំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិ តម្រូវឱ្យមានការសិក្សាស្រាវជ្រាវ ជាលក្ខណៈវិទ្យាសាស្ត្រពីផលប៉ះពាល់ និងបញ្ហាប្រឈមផ្សេងៗ ពីសំណាក់ភាគីពាក់ព័ន្ធយ៉ាងល្អិតល្អន់ និងស៊ីជម្រៅប្រកបដោយសុភវិនិច្ឆ័យត្រឹមត្រូវ ព្រមទាំងមានការចូលរួមពិនិត្យតាមដាន និងវាយតម្លៃដោយយកចិត្តទុកដាក់ ពីដៃគូនានាដើម្បីជាទឡ្ហីករណ៍គាំទ្រនូវវិធានការ ដែលធ្វើឱ្យការប្រឡងអាចសម្រេចបានតាមគោលដៅដែលបានរំពឹងទុក។

## A brief summary

In many developing countries around the world, there is a focus on reform in all sectors to improve human resources and the growth of the nation from year to year. Improving one's ability and skills is given a central priority to motivate the country for sustainable development.

As an Education Officer and Researcher, please join us for a dissertation on “Effectiveness of Higher Secondary Examination Examination 2017-2018” which aims to improve the quality of education and to improve Student ability during exams. More specifically, to eliminate corruption during the exam and the Ministry of Education has implemented this reform program from 2014 to the beginning of 2018, the Ministry of Education has been implementing for the last 5 years and has been doing so. Continue to implement this program. The other is for the purpose:

1). Discover the mechanisms that make high school diploma exams more effective and effective.
2). Identify the challenges and irregularities during high school diploma examinations

Therefore, in order to achieve quality and efficiency through reform, the Higher Secondary Examination requires a thorough and in-depth study of the implications and challenges of relevant stakeholders. Partnering, monitoring and evaluation by partners Harmonization among the arguments supporting measures that make the exam can achieve the expected goal.

# មាតិកា

**សេចក្តីប្រកាសអះអាងរបស់បេក្ខជន**

**លិខិតបញ្ជាក់**

**សេចក្តីថ្លែងអំណរគុណ**

**មូលន័យសង្ខេប**

**១.សេចក្តីផ្តើម**........................................................................................១

១.១.សាវតាស្រាវជ្រាវ........................................................................២

១.២.ចំណោទបញ្ហា នៃការស្រាវជ្រាវ....................................................៦

១.៣.គោលបំណង នៃការស្រាវជ្រាវ.......................................................៦

១.៤.សំណួរស្រាវជ្រាវ.........................................................................៧

១.៥.សារៈសំខាន់ នៃការស្រាវជ្រាវ.......................................................៧

១.៦.ដែនកំណត់ នៃការស្រាវជ្រាវ.........................................................៧

១.៦.១.វិសាលភាព នៃការស្រាវជ្រាវ...................................................៧

១.៦.២.ដែនកំណត់ នៃការស្រាវជ្រាវ...................................................៨

១.៧.រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ......................................................៨

**២.រំលឹកទ្រឹស្តី**........................................................................................១០

២.១.ពន្យល់ពាក្យគន្លឹះ........................................................................១១

២.២.ប្រវត្តិនៃការប្រឡង......................................................................១១

២.៣.ទម្រង់ នៃការប្រឡងសម័យបុរាណ...................................................១១

២.៤.ទម្រង់ នៃការប្រឡងសម័យបច្ចុប្បន្ននៅកម្ពុជា (២០១៤-២០១៨)...................១២

២.៥.អំពីការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ.....................................១៦

២.៥.១.គុណភាពនាយកសាលា............................................................១៧

២.៥.២.គុណភាពកម្មវិធីសិក្សា.............................................................១៩

២.៥.៣.គុណភាពគ្រូ.........................................................................១៩

២.៥.៤.គុណភាពសិស្ស.......................................................................២០

២.៥.៥.ការជំរុញ និងលើកទឹកចិត្តពីមាតាបិតាសិស្ស.....................................២០

២.៥.៦.អង្គភាពប្រឆាំងអំពើពុករលួយ (ACU)............................................២១

២.៦.ប្រសិទ្ធភាព នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ........................២១
២.៧.បទប្បញ្ញត្តិចំពោះបេក្ខជន និងបុគ្គលិកអប់រំ សម្រាប់ការប្រឡង
សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ.......................................................................២២
**៣.វិធីសាស្ត្រស្រាវជ្រាវ**..........................................................................................២៤
៣.១.ការជ្រើសរើសភាគសំណាក.......................................................................២៥
៣.២.ឧបករណ៍ស្រាវជ្រាវ...................................................................................២៧
៣.២.១.វិធីបង្កើតកម្រងសំណួរ......................................................................២៧
៣.២.២.លក្ខណៈទម្រង់កម្រងសំណួរសម្ភាសន៍..............................................២៨
៣.៣.នីតិវិធី និងដំណើរការប្រមូលទិន្នន័យ.........................................................២៨
៣.៤.ការវិភាគទិន្នន័យ........................................................................................៣០
**៤.លទ្ធស្រាវជ្រាវ**................................................................................................៣១
៤.១.លទ្ធផល នៃការសម្ភាសសិស្សថ្នាក់ទី១២...................................................៣៤
៤.២.លទ្ធផល នៃការសម្ភាសលោកគ្រូ អ្នកគ្រូ ដែលបង្រៀនថ្នាក់ទី១២
និងធ្លាប់ជាគណៈកម្មការប្រឡង.......................................................................៤៨
៤.៣.លទ្ធផល នៃការសម្ភាសនាយក ឬគណៈគ្រប់គ្រងសាលា............................៥៩
៤.៤.លទ្ធផល នៃការសម្ភាសមាតាបិតា ឬអាណាព្យាបាលសិស្សថ្នាក់ទី១២.........៦៦
**៥.សេចក្តីសន្និដ្ឋាន**...............................................................................................៧៣
៥.១. សេចក្តីសន្និដ្ឋាន.......................................................................................៧៤
៥.២. អនុសាសន៍...............................................................................................៧៥
៥.២.១.អនុសាសន៍សម្រាប់ក្រសួងអប់រំ និងភាគីពាក់ព័ន្ធ.........................៧៥
៥.២.២.អនុសាសន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត...............................៧៥

**ឧបសម្ព័ន្ធ/កម្រងសំណួរ**......................................................................................................៧៦
កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា......................................................................៧៧
កម្រងសំណួរសម្រាប់គ្រូបង្រៀន.......................................................................................៨១
កម្រងសំណួរសម្រាប់សិស្សថ្នាក់ទី១២.............................................................................៨៤
កម្រងសំណួរសម្រាប់មាតាបិតាសិស្សថ្នាក់ទី១២................................................................៨៨
**ឯកសារយោង**..................................................................................................................៩១

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១.សាវតារស្រាវជ្រាវ

ការអប់រំ មានសារៈសំខាន់ណាស់ក្នុងការកសាងធនធានមនុស្ស និងការអភិវឌ្ឍប្រទេសជាតិទាំងមូល។ ស្របគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកំណែទម្រង់លើវិស័យអប់រំទាំង១៥ចំណុច ដើម្បីធ្វើឱ្យប្រសិទ្ធភាពនៃការអប់រំកាន់តែប្រសើរឡើង *(កំណែទម្រង់ ១៥ចំណុច ឆ្នាំ២០១៦ ឯកសារអប់រំខ្មែរ)*។

ក្នុងនោះផងដែរ ចំណុចទី៧នៃកំណែទម្រង់ទាំង១៥ចំណុចនេះ គឺក្រសួងអប់រំបានដាក់ចេញនូវកម្មវិធី "**កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**" ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវ គុណភាពអប់រំ និងដើម្បីពង្រឹងនូវសមត្ថភាពសិស្សក្នុងពេលប្រឡង ជាពិសេសទៅទៀតនោះ ដើម្បីលុបបំបាត់អំពើពុករលួយផ្សេងៗនៅក្នុងពេលប្រឡង ហើយក្រសួងអប់រំបានអនុវត្តកម្មវិធីកំណែទម្រង់នេះ គឺចាប់ពីឆ្នាំ២០១៤ គិតមកដល់ដើមឆ្នាំ២០១៨នេះ ក្រសួងអនុវត្តបាន០៥ឆ្នាំកន្លងមកហើយ ហើយបាននឹងកំពុងបន្តអនុវត្តកម្មវិធីនេះជាបន្តទៅទៀត។

រាជរដ្ឋាភិបាល នឹងផ្តោតលើការយកចិត្តទុកដាក់លើវិស័យអភិវឌ្ឍធនធានមនុស្ស ដែលនឹងធានាបាននូវការប្រគួតប្រជែងក្នុងទីផ្សារពលកម្មក្នុងតំបន់ដែលកាន់តែបើកចំហ តាមរយៈ ១)ការបណ្តុះបណ្តាលពលករឱ្យមានជំនាញ និងផលិតភាពខ្ពស់តាមសេចក្តីត្រូវការនៃទីផ្សារ និងអាចបង្កើតតម្លៃបន្ថែមខ្ពស់ ២)ការរៀបចំក្របខណ្ឌគតិយុត្ត និងកសាងស្ថាប័នអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៣)លើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមក្នុងកិច្ចការនេះ និង ៤)ការពង្រឹងគុណភាពនៃការអប់រំ និងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ **នវនុវត្តន៍**(Innovation) *(ក្រសួងអប់រំ យុវជន និងកីឡា ទំព័រ១៣)*។

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយ គុណភាព សមត្ថភាព និងគុណធម៌ជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេសទាំងពេលចំពោះមុខ និងសម្រាប់អនាគត។ ជាពិសេស ក្នុងពេលដែលកម្ពុជាឈានចូលទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងពេលដ៏ខ្លីខាងមុខនៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០តាមចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ការអភិវឌ្ឍធនធានមនុស្សគឺ សំដៅទៅលើការកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើ សហគ្រិនភាព ជំនាញការច្នៃប្រឌិត និងនវានុវត្តន៍លើគ្រប់ផ្នែក គ្រប់វិស័យ ពិសេសផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ព្រមទាំងសមត្ថភាពក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍ។ ទន្ទឹមនឹងនេះ ការលើកស្ទួយគុណភាពផ្នែកសុខភាព កាយសម្បទា សីលធម៌ ស្មារតីទទួលខុសត្រូវ និងស្មារតីស្នេហាជាតិ និងវិជ្ជាជីវៈ ដោយគ្មានការរើសអើងខាងយេនឌ័រ រួមជាមួយនិងប្រព័ន្ធសង្គមគត់មត់*(ផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ២០១៤-២០១៨, ទំព័រ១៤)*។

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយ គុណភាព និងសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការ ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា ដែលជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេសទាំងក្នុងពេលចំពោះមុខ និងសម្រាប់អនាគតរយៈពេលវែង នៅតែជាបញ្ហាប្រឈមដ៏ចម្បងរបស់រាជរដ្ឋាភិបាល។ ជាក់ស្ដែងក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលត្រូវបានបន្តផ្ដោតអាទិភាពលើ ការពង្រឹងគុណភាព ភាពអាចឆ្លើយតបបានទៅនឹងសេចក្ដីត្រូវការនៃទីផ្សារពលកម្ម និងការអភិវឌ្ឍជំនាញបច្ចេកទេសសម្រាប់យុវជន ដើម្បីបង្កើនឱកាសការងារ និងប្រើប្រាស់ឱ្យអស់នូវសក្ដានុពល នៃផលលាភប្រជាសាស្ត្ររបស់កម្ពុជាក៏ដូចជាដើម្បីធានាការបន្តវេនក្នុងការដឹកនាំ និងអភិវឌ្ឍប្រទេស *(ផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ២០១៤-២០១៨,ទំព័រ១៤)*។

**ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា** កសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជា

សង្គមរីកចម្រើនផ្អែកលើចំណេះដឹង ចំណេះធ្វើជាមូលដ្ឋាន*(ផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ២០១៤-២០១៨,ទំព័រ១៤)*។

គោលបំណងសំខាន់ នៃគោលដៅអប់រំរយៈពេលវែងនោះ គឺអប់រំមនុស្សដើម្បីឱ្យក្លាយទៅជាពលរដ្ឋល្អ ស្របតាមគំនិតនៃទស្សនវិទូដ៏ល្បីល្បាញរបស់ក្រិក គឺលោក **អារីស្តូត** (Aristotle) បានពន្យល់ថា "ភាពជោគជ័យរបស់រាជរដ្ឋាភិបាលមួយ គឺផ្អែកលើគុណភាពនៃការអប់រំ ដែលត្រូវផ្តល់ដល់យុវជនក្មេងៗ និងជាកម្លាំងដ៏មុតស្រួចក្នុងសង្គមនោះ" ។ ចំណែកឯលោក **ថមមើ ជេហ្វើសិន** (Thomas Jeffersom) បាននិយាយថា បើសេចក្តីរំពឹងរបស់ជាតិមួយ ដែលសម្បូរទៅដោយភាពល្ងង់ខ្លៅ និងភាពទំនេរគ្មានការងារធ្វើ ស្ថិតក្នុងរដ្ឋាភិបាលស៊ីវិល័យមួយនោះ សេចក្តីរំពឹងនឹងមិនអាចកើតឡើងបានឡើយ ហើយថែមទាំងបានបំផ្លាញរដ្ឋាភិបាលស៊ីវិល័យនោះថែមទៀត។ លើសពីនេះទៅទៀត អ្នកប្រវត្តិវិទូរបស់សហរដ្ឋអាមេរិក គឺលោក **ហង់រីស្ទីលកុមាជើ** (Henry Steel Commager) បានធ្វើការសន្និដ្ឋានថា ថ្ងៃដំបូងបំផុតនៃជាតិសាសន៍ថ្មីអាមេរិកាំងកើតឡើង គឺសាលារៀន ដែលជាអ្នកទទួលខុសត្រូវចំពោះវាសនាពលរដ្ឋអាមេរិកម្នាក់ៗតាមរយៈចំណេះដឹង។ លោកបានពន្យល់ទៀតថា គោលដៅទីពីរនៃការអប់រំ គឺការច្នៃប្រឌិត និងការពង្រឹងគំនិតនៃសហគមន៍ជាតិ ដែលជាការអភិវឌ្ឍជាតិមួយ ឱ្យរីកចម្រើន ហើយវាក្លាយទៅជាផ្ទៃដីមួយនៃជនអន្តោប្រវេសន៍គ្រប់ទីកន្លែង សាលារៀនអាចជួយលើកកម្ពស់គំនិតបញ្ញាញាណរបស់សហគមន៍ និងអត្តសញ្ញាណជាតិ*(ប្រភពឯកសារ៖ ដកស្រង់ចេញពីនិក្ខេបបទ លោក ចាន់ ធឿន និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៤ ទំព័រ២ នៃវិទ្យាស្ថានជាតិអប់រំ)*។

សម្រាប់គរុវិទូ **ចន ដេវី** (John Dewey) បញ្ញត្តិ "**ការអប់រំ**" ត្រូវបានកំណត់ន័យថា ជាការអភិវឌ្ឍនូវរាល់លទ្ធភាពទាំងឡាយ ដែលមាននៅក្នុងបុគ្គល ដែលនឹងជួយឱ្យគេ គ្រប់គ្រងបរិស្ថានរស់នៅ និងអាចបំពេញនូវលទ្ធភាពទាំងឡាយរបស់គេ ហើយការអប់រំនោះ គឺផ្តើមចេញពីលទ្ធភាពខាងក្នុងរបស់មនុស្ស។ ក្នុងន័យមួយទៀត លោកបានឱ្យនិយម័យថា ការអប់រំ គឺជាដំណើរនៃការកសាងឡើងវិញ ឬក៏ការប្រមូលផ្តុំឡើងវិញនូវបទពិសោធន៍ដោយផ្តល់ឱ្យវានូវតម្លៃបន្ថែមទៀតតាមរយៈការធ្វើឱ្យប្រសើរឡើងខាងប្រសិទ្ធភាពសង្គមដែលកំពុងវិវត្ត។ តាមន័យទាំងពីរ

ខាងលើនេះ សម្រាប់លោក ចន ដេវី ការអប់រំគឺជាដំណើរការគ្រប់គ្រងមួយ ដែលផ្អែកលើដំណើរការទាំងនេះ ការអភិវឌ្ឍលទ្ធភាពទាំងឡាយរបស់សង្គម គឺជាការអភិវឌ្ឍលទ្ធភាពទាំងឡាយរបស់មនុស្ស។ មួយវិញទៀត បើជីវិតជាផ្នែករបស់សង្គម ដែលរីកចម្រើនឥតឈប់ឈរ ដូច្នេះការអប់រំជីវិតក៏ជាការវិវត្តឥតឈប់ឈរដែរ ហើយរាល់លទ្ធភាពរបស់មនុស្សពិតជាត្រូវបានបញ្ចូលយ៉ាងប៉ិនប្រសប់ទៅក្នុងវិសាលភាពមួយ ដែលគ្រប់ការរីកចម្រើនរបស់សង្គមកើតឡើង*(source: John_Dewey_Democracy and Education An Introduction to the Philosophy of Education.)*។

**ចំណុចទី៧៖** កំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិ (កែលម្អយន្តការកំណែ និងប្រព័ន្ធពិនិត្យតាមដាន កែលម្អសង្ខេបមេរៀន កំណែលម្អយន្តការបូកស្រង់ អនុម័តមេរៀនសង្ខេបប្រវត្តិសាស្ត្រទី១២ ***(កំណែទម្រង់១៥ចំណុច ឆ្នាំ២០១៦ ឯកសារអប់រំខ្មែរ)***។

បន្ទាប់ពីការធ្វើកំណែទម្រង់ នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនាឆ្នាំ២០១៤ ដោយរដ្ឋមន្ត្រីអប់រំថ្មី លោក **ហង់ជួន ណារ៉ុន** កន្លងមក ការអប់រំគឺមានលក្ខណៈល្អប្រសើរច្រើនឡើងវិញគួរឱ្យកត់សម្គាល់ គឺក្រសួងបានដាក់ចេញនូវគោលការកំណែទម្រង់១៥ចំណុច ដែលធ្វើឱ្យសិស្សគ្រប់រូបមានការយកចិត្តទុកដាក់ក្នុងការរៀនសូត្រ និងមានបម្រុងប្រយ័ត្ន ដោយធ្វើយ៉ាងណាដើម្បីប្រឡងជាប់ ដោយសរបញ្ជាក់ពីសមត្ថភាពរបស់បេក្ខជនម្នាក់ៗក្នុងការបង្ហាញពីចំណេះដឹងរបស់ពួកគេយ៉ាងពិតប្រាកដ។ ពេលនោះ រដ្ឋមន្ត្រីអប់រំបានលើកឡើងថា "សូមបេក្ខជនទាំងអស់ចងចាំថា លទ្ធផលនៃការប្រឡងនេះ ឆ្លុះបញ្ចាំងនូវសារៈសំខាន់បីយ៉ាងគឺទី(១) **អ្នកចេះគឺជាប់** ទី(២) ការប្រឡងបានប្រព្រឹត្តទៅដោយ **យុត្តិធម៌ តម្លាភាព គោលការណ៍ច្បាប់ និងលទ្ធផលទទួលយកបាន** ទី(៣) លទ្ធផលនៃការប្រឡងពុំមែនជាការកំណត់វាសនារបស់បេក្ខជនទេ ប៉ុន្តែគឺជាការវាស់ស្ទង់សមត្ថភាព និងជំរុញឱ្យមានការខំប្រឹងបន្តទៅមុខទៀត។ (ដកស្រង់ចេញពីសារលិខិតរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ) ***(Facebook moeys Cambodia)*** ។

## ១.២.ចំណោទបញ្ហា នៃការស្រាវជ្រាវ

ដោយយល់ឃើញថា ការប្រឡងមធ្យមសិក្សាទុតិយភូមិនាឆ្នាំសិក្សាកន្លងមកមានចំណុចខ្វះចន្លោះ និងមានបញ្ហាប្រឈម(អំពើពុករលួយ) មួយចំនួនកើតឡើងទើបក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់ថ្មីទាំង១៥ចំណុច*(ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៤)។* ក្នុងនោះផងដែរកំណែទម្រង់ចំណុចទី៧ គឺផ្តោតសំខាន់ទៅលើការប្រឡងសញ្ញាបត្រមធម្យមសិក្សាទុតិយភូមិ ដែលរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោកបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** បានអនុវត្តកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិភូមិនេះជាលើកដំបូងនាឆ្នាំ២០១៤ គោលបំណងគឺចង់ធ្វើឱ្យប្រសើរឡើងនូវ គុណភាព សមត្ថភាពចំណេះដឹងពិតប្រាកដរបស់បេក្ខជនប្រឡងម្នាក់ៗ ជាពិសេស គឺចង់លុបបំបាត់អំពើពុករលួយ និងភាពមិនប្រក្រតីផ្សេងៗនៅក្នុងពេលប្រឡងសញ្ញាបត្រ។ ជាពិសេសទៅទៀត តាមរយៈការអនុវត្តកំណែទម្រង់នេះ នឹងធ្វើឱ្យសមត្ថភាពសិស្សមានការរីកចម្រើន សិស្សមានការប្រុងប្រយ័ត្នក្នុងការប្រឡង មានការប្រឹងប្រែងរៀនសូត្រ ពង្រឹងសមត្ថភាពរបស់ខ្លួន និងមានភាពយុត្តិធម៌ តម្លាភាពក្នុងការប្រឡង ដោយមានជំនឿថា **"អ្នកចេះ គឺជាប់"** ពិតប្រាកដ*(របាយការប្រជុំណែនាំមុនថ្ងៃប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិភូមិ ក្រសួងអប់រំ) ។*

## ១.៣.គោលបំណង នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងចង់ស្វែងរកឱ្យឃើញនូវចំណុចមួយចំនួនដូចខាងក្រោម៖

(១). **រកឱ្យឃើញពីយន្តការនានា** ដែលធ្វើឱ្យការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់ថែមទៀត

(២). **រកឱ្យឃើញពីបញ្ហាប្រឈម និងភាពមិនប្រក្រតីផ្សេងៗ** ក្នុងពេលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## ១.៤.សំណួរស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះគឺធ្វើឡើងដើម្បីឆ្លើយតបទៅនឹងសំណួរដូចខាងក្រោមៈ

(១). តើក្រសួងអប់រំ យុវជន និងកីឡា និងភាគីពាក់ព័ន្ធ ត្រូវរៀបចំយន្តការបែបណាខ្លះ ដើម្បីឱ្យការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានប្រសិទ្ធភាពល្អ?

(២). តើមានបញ្ហាប្រឈម និងភាពមិនប្រក្រតីអ្វីខ្លះ ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនាឆ្នាំសិក្សា២០១៧-២០១៨ កន្លងមក?

## ១.៥.សារៈសំខាន់ នៃការស្រាវជ្រាវ

ការស្រាវជ្រាវមួយនេះមានសារៈសំខាន់ដូចខាងក្រោមៈ

បង្កើនទំនុកចិត្តដល់សាធារណជន មាតាបិតាសិស្សឱ្យមានភាពជឿជាក់លើការប្រឡងក៏ដូចជាបានលើកកម្ពស់វិស័យអប់រំ

ធ្វើឱ្យសាធារណជនទទួលយកបានអំពីលទ្ធផល និងប្រសិទ្ធភាពនៃការប្រឡងសញ្ញាបត្រ តាមរយៈកំណែទម្រង់នេះ

យល់បានពីបញ្ហាលុបបំបាត់ អំពើពុករលួយផ្សេងៗ តាមរយៈកម្រែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់ទុកជាទុនឯកសារ ដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗទៀត

## ១.៦.ដែនកំណត់ នៃការស្រាវជ្រាវ

### ១.៦.១.វិសាលភាព នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះ បានកំណត់យកសាលាមធ្យមសិក្សាចំណោះទូទៅមួយចំនួននៅក្នុងខេត្តកំពត គឺៈ

**ឈ្មោះសាលាទី១៖** វិទ្យាល័យអង្គ រមាស (ស្រុកដងទង់)

**ឈ្មោះសាលាទី២៖** វិទ្យាល័យប៊ុន រ៉ានី ហ៊ុន សែន ដងទង់ (ស្រុកដងទង់)

**ឈ្មោះសាលាទី៣៖** វិទ្យាល័យ ហ៊ុន សែន ឈូក (ស្រុកឈូក)

**ឈ្មោះសាលាទី៤៖** វិទ្យាល័យ ហ៊ុន សែន អង្គចក (ស្រុកជុំគីរី)

### ១.៦.២.ដែនកំណត់ នៃការស្រាវជ្រាវ

នាយក/នាយិកា នាយករង/នាយិការង ចំនួន១២នាក់

លោកគ្រូ អ្នកគ្រូ ចំនួន៤០នាក់

សិស្ស(បញ្ចប់ទី១២ និងត្រៀមប្រឡងទី១២) ចំនួន៨០នាក់

មាតាបិតាសិស្ស/អាណាព្យាបាល ចំនួន២០នាក់

សរុបរួមមានចំនួន ១៥២នាក់ ។

## ១.៧.រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា៥ជំពូកធំៗ ដូចខាងក្រោម៖

### ជំពូកទី១ ៖ សេចក្ដីផ្ដើម

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវបានកំណត់សមាសភាគ៧ចំណុចគឺ (១) សាវតារ នៃការស្រាវជ្រាវ (២) ចំណោទបញ្ហានៃការស្រាវជ្រាវ (៣) គោលបំណងនៃការស្រាវជ្រាវ (៤)សំណួរស្រាវជ្រាវ (៥) សារៈសំខាន់នៃការស្រាវជ្រាវ (៦) ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ និង (៧) រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

### ជំពូកទី២ ៖ រំលឹកទ្រឹស្ដី

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវ បានប្រមែប្រមូលទ្រឹស្ដីចាស់ៗ ពីអ្នកសិក្សាស្រាវជ្រាវមុនៗ ដែលមានខ្លឹមសារទាក់ទងនឹងប្រធានបទរបស់និក្ខេបបទ និងកម្រងសំណួរសម្រាប់សម្ភាសដើម្បីលើកយកមកបង្ហាញ និងការពារអំណះអំណាងក្នុងនិក្ខេបបទសម្រាប់ស្រាវជ្រាវ និងបង្កើតស្នាដៃថ្មីនេះឡើង។

**ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ**

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសគំរូ និងប្រភេទគំរូ និងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យ។

**ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា**

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងយកទិន្នន័យ ដែលប្រមូលបានមកវិភាគ និងបកស្រាយយ៉ាងក្បោះក្បាយ និងស៊ីជម្រៅដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវកែលម្អក្នុងស្ថានភាពជាក់ស្តែងនៃការអនុវត្តកម្មវិធីកំណែទម្រង់វិស័យអប់រំមួយនេះ។

**ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងធ្វើការសន្និដ្ឋានលើគ្រប់ចំណុច ដែលបានវិភាគមកខាងលើ និងផ្តល់ជាគំនិតយោបល់ធ្វើសំណូមពរទៅលើចំណុចមួយចំនួន ដែលត្រូវកែលម្អដើម្បីជាការចូលរួមចំណែក ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់មួយនេះ ឱ្យកាន់តែមានភាពល្អប្រសើរឡើង។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១.ពន្យល់ពាក្យគន្លឹះ

**ប្រសិទ្ធភាព** (ន) ភាពដែលតាក់តែងហើយ ភាពដែលធ្វើឱ្យសម្រេចហើយ ភាពធ្វើឱ្យពេញគ្រប់គ្រាន់*(វចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត គ.ស១៩៦៧)*។

**ប្រសិទ្ធភាព** (Effectiveness) ជាលំនាំ ឬដំណើរការក្នុងសកម្មភាពការងារណាមួយ ដើម្បីឱ្យសម្រេចលទ្ធផលល្អក្នុងការអនុវត្ត *(ឌី ប៊ុណ្ណា នាយករងវ.ជ.អ)*។

**កំណែទម្រង់** (ន) ការធ្វើការកែតម្រូវ ការកែលម្អឡើងវិញឱ្យប្រសើរឡើង នូវការងារអ្វីមួយ (បទានុក្រមពាក្យបច្ចេកទេសថ្មី)។

**ការប្រឡង** (ន) ការល្បងឱ្យឃើញកម្លាំង ការប្រណាំង ការសាកគ្នា ការធៀបគ្នាមើល។ *(វចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត គ.ស១៩៦៧)*។

**យន្តការ** ជាដំណើរការ ឬការប្រព្រឹត្តទៅ នៃសកម្មភាពអ្វីមួយ (បទានុក្រមពាក្យបច្ចេកទេសថ្មី)។

## ២.២.ប្រវត្តិនៃការប្រឡង

ជាទូទៅការប្រឡងត្រូវបានចាត់ទុកថា ជាផ្នែកមួយនៃការបង្រៀន។ ការប្រឡងជាវិធីមួយដើម្បីវាស់លទ្ធផល អំពីចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស។ ការប្រឡងថ្នាក់ជាតិបានវាយតម្លៃពីសមិទ្ធផល នៃការអប់រំរបស់សិស្សសម្រាប់ការឱ្យពិន្ទុ ការឡើងថ្នាក់ ឬសម្រាប់ការបញ្ជូនសិស្សទៅតាមគ្រឹះស្ថានអប់រំនានា ត្រូវបានគេប្រើប្រាស់ជាមធ្យោបាយនៃការវាយតម្លៃមួយក្នុងប្រទេសភាគច្រើនបំផុតនៅលើពិភពលោក ***(ឯកសារក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងបច្ចេកទេស ឆ្នាំ២០១៥, ទំព័រ៤៥)***។

## ២.៣.ទម្រង់ នៃការប្រឡងសម័យបុរាណ

កាលដើមឡើយ ការសិក្សារៀនសូត្រត្រូវបានធ្វើឡើង ដើម្បីគ្រាន់តែឱ្យសិស្សបានយល់ជ្រួតជ្រាបអំពីបញ្ញត្តិ ដែលត្រូវរៀបចំទុកតែប៉ុណ្ណោះ។ ការរៀនសូត្រនៅតាមតំបន់នីមួយៗ មាន

លក្ខណៈខុសៗគ្នាទៅតាមបរិបទនៃតំបន់នោះ ហើយអ្នកអប់រំសម័យដើម មិនទាន់ចេះរៀបចំចង ក្រងនូវកម្មវិធីសិក្សាឱ្យបានច្បាស់លាស់ទេ។ ចំណែកឯការប្រឡងវិញ គឺគ្រាន់តែជាការដាក់ សំណួរផ្ទាល់មាត់ ឬការធ្វើតេស្តបែបជាការអនុវត្តបញ្ចេញសកម្មភាពជាក់ស្តែង ដើម្បីទទួលបាន មុខតំណែង ឬតួនាទី។ បើយោងតាមឯកសារខ្លះបង្ហាញថាការប្រឡងនៅសាលារៀន ត្រូវបានធ្វើ ឡើងដំបូងដោយលោក **ឃ្វីនទីលាន** (Quintilian) គឺជាមន្ត្រីរដ្ឋាភិបាលម្នាក់នៅក្នុងអាណាចក្រ រ៉ូម។ ការអនុវត្តការប្រឡង គឺធ្វើឡើងតែក្នុងព្រះវិហារសុទ្ធ។ តែបើតាមការចូលរួមរបស់អ្នកផ្តល់ ចម្លើយម្នាក់នៅក្នុងGoogle.com បានឱ្យដឹងថាការប្រឡងដំបូងបង្អស់ គឺត្រូវបានធ្វើឡើងនៅ ប្រទេសចិន ដោយរដ្ឋាភិបាលបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់រដ្ឋ។ ប្រទេសចិន គឺជា ប្រទេសដំបូងគេ ដែលបានរៀបចំការប្រឡងមានលក្ខណៈស្តង់ដារជាតិ ដែលឱ្យឈ្មោះថា "Imperial Examination"។ នៅក្នុងពេលនោះគោលបំណងនៃការប្រឡង គឺការជ្រើសរើសបេក្ខជន សម្រាប់តំណែងដ៏ជាក់លាក់មួយក្នុងជួររដ្ឋាភិបាល។ ការប្រឡងដែលមានឈ្មោះថា "Imperial Examination"នេះ ត្រូវបានបង្កើតឡើងក្នុងសម័យកាល Sui Dynasty ៦០៥ មុនគ.ស ហើយបាន បញ្ចប់ទៅវិញនៅចុងសម័យកាល Quing Dynasty ។ ហើយក្រោយមកប្រទេសអង់គ្លេស ក៏បាន កែសម្រួលប្រព័ន្ធនៃការប្រឡងនេះនៅឆ្នាំ១៨០៦ ដើម្បីជ្រើសរើសបេក្ខជនពិសេស សម្រាប់ តំណែងនៅក្នុងកិច្ចការងារជាជំនួយការរបស់ព្រះអង្គម្ចាស់ក្សត្រី។ ប្រព័ន្ធនៃការប្រឡងនេះ ត្រូវ បានដាក់បញ្ចូលទៅក្នុងការអនុវត្ត ហើយចាប់ផ្តើមអនុវត្តពាសពេញពិភពលោក ដែលក្លាយទៅជា តេស្តស្តង់ដារអប់រំ ដែលមានលក្ខណៈទូលំទូលាយ។

*(Source(s): http:/en.wikipedia.org/wiki/Examination...)*

## ២.៤.ទម្រង់ នៃការប្រឡងសម័យបច្ចុប្បន្ននៅកម្ពុជា (២០១៤-២០១៨)

ដោយមើលឃើញពីបញ្ហាប្រឈមផ្សេងៗ ចំពោះការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយ ភូមិនាមុនឆ្នាំ២០១៤កន្លងមកដូចជា បញ្ហាអំពើពុករលួយផ្សេងៗ បញ្ហាចំណេះដឹងសិស្សមិនសូវ មានគុណភាព សញ្ញាបត្រមិនត្រូវបានសាធារណជនឱ្យតម្លៃ និងបញ្ហានៅពេលបំពេញការងារ ជាដើម មូលហេតុដោយសារការអប់រំពុំសូវមានគុណភាព។ ដូច្នេះហើយ បានជានៅឆ្នាំ២០១៤

ក្រសួងអប់រំ យុវជន និងកីឡា ដែលមានលោកបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់លើវិស័យអប់រំចំនួន១៥ចំណុចគឺៈ

**ទី១:កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** (អនុវត្តប្រព័ន្ធព័ត៌មានក្នុងការគ្រប់គ្រងបណ្តុះបណ្តាលមន្ត្រីលទ្ធកម្មធ្វើប្រតិបត្តិការសាវនកម្មផ្ទៃក្នុង)

**ទី២: ការពង្រាយគ្រូបង្រៀន** (កែសម្រួលក្របខណ្ឌឡើងវិញ វាយតម្លៃ និងស្វ័យប្រកាសពីស្ថានភាពលើស និងខ្វះគ្រូ បញ្ចូលសាលាសហគមន៍ពហុភាសា៥០ឱ្យចូលជាភាសារដ្ឋ បញ្ចូលគ្រូអ៊ីស្លាម១៨០០នាក់ គ្រូជនជាតិដើមភាគតិច២០នាក់ក្នុងក្របខណ្ឌ)

**ទី៣: កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន** (អភិវឌ្ឍន៍មជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងបាត់ដំបងទៅជាវិទ្យាស្ថានគរុកោសល្យ។ អនុម័តស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ រៀបចំស្តង់ដារគ្រូបង្រៀន និងឯកសារទស្សនៈទានស្តីពីគន្លងអាជីពគ្រូបង្រៀន។)

**ទី៤: លើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន** (អនុវត្តប្រព័ន្ធក្រេឌីត សម្រាប់វាយតម្លៃសមត្ថភាពបុគ្គលិកអប់រំ បង្កើតការិយាល័យគាំទ្រគ្រូបង្រៀន និងរៀបចំគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន ប្រព័ន្ធពន្លឿន)

**ទី៥: ការងារអធិការកិច្ច** (រៀបចំសៀវភៅស្តីពីអធិការកិច្ចតាមកាលកំណត់ និងឧបករណ៍អធិការកិច្ច អភិវឌ្ឍន៍សមត្ថភាពអធិការកិច្ច រៀបចំរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិជា៨តំបន់អធិការកិច្ច សាកល្បងអធិការកិច្ចតាមកាលកំណត់៧០សាលា)

**ទី៦: វង្វាយតម្លៃលទ្ធផលសិក្សា** (ផ្សព្វផ្សាយលទ្ធផលតេស្តថ្នាក់ជាតិថ្នាក់ទី៣ និងទី៨ លើមុខវិជ្ជាភាសាខ្មែរ រូបវិទ្យា និងគណិតវិទ្យា ធ្វើតេស្តវាយតម្លៃថ្នាក់តំបន់សាកល្បង៣៥សាលាធ្វើតេស្តវាយតម្លៃកម្រិតអន្តរជាតិសាកល្បង សម្រាប់ការអភិវឌ្ឍ៥៦សាលា ធ្វើតេស្តល្បឿនអំណាន)

**ទី៧: កំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិ** (កែលម្អយន្តការកំណែ និងប្រព័ន្ធពិនិត្យតាមដាន កែលម្អសង្ខេបមេរៀន កំណែលម្អយន្តការបូកស្រង់ អនុម័តមេរៀនសង្ខេបប្រវត្តិសាស្ត្រថ្នាក់ទី១២។)

**ទី៨: កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល** (ដាក់ឱ្យប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេស ផ្សព្វផ្សាយក្របខណ្ឌកម្មវិធីចំណេះទូទៅ និងអប់រំបច្ចេកទេស រៀបចំកម្មវិធីសិក្សាលម្អិត និងស្តង់ដារមុខវិជ្ជាឯកទេស រៀបចំគ្រូតែងសេចក្តី)

**ទី៩: ការសាងសង់អគារសិក្សា និងជួសជុល** (ជួសជុល និងកែលម្អមណ្ឌលប្រឡងមធ្យមសិក្សាទុតិយភូមិ ដាក់ដំណើរការសាលាជំនាន់ថ្មីនៅវិទ្យាល័យព្រះស៊ីសុវត្ថិ សាងសង់បង្គន់អនាម័យ កន្លែងលាងដៃ ប្រព័ន្ធទឹកស្អាត)

**ទី១០: វាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា** (កែលម្អនីតិវិធី និងដំណើរការទទួលគុណភាព អភិវឌ្ឍន៍ប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យាឧត្តមសិក្សា ព្រាងឯកសារស្តីពី ការធានាគុណភាពអប់រំផ្ទៃក្នុងកម្រិតកម្មវិធីសិក្សា)

**ទី១១: លើកកម្ពស់វិស័យកីឡា** (រៀបចំការប្រគួតកីឡាជាតិ ផ្សព្វផ្សាយការអនុវត្តសៀវភៅអប់រំកាយកម្រិតបឋមសិក្សា អនុម័តកម្មវិធីសិក្សាអប់រំកាយនៅមធ្យមសិក្សាបឋមភូមិ ជួសជុលកែលម្អហេដ្ឋារចនសម្ព័ន្ធកីឡា បណ្តុះបណ្តាលធនធានមនុស្សថ្នាលកីឡាករក្រុមជម្រើសជាតិ)

**ទី១២: ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន** (ក្រុមប្រឹក្សាយុវជន និងកុមារ ដើម្បីជំរុញបង្កើតក្លឹបសិក្សាតាមសាលាវិទ្យាល័យ អនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញខ្លីដំណើរការមជ្ឈមណ្ឌលព័ត៌មានទីផ្សារ អនុវត្តកម្មវិធីសហគ្រាស សហាគមន៍ និងកម្មវិធីសហគ្រិនភាព)។

**ទី១៣: ការអប់រំបច្ចេកទេស** (អនុម័តក្របខណ្ឌកម្មវិធីអប់រំ បំណិនជីវិតថ្នាក់ទី៤ ដល់ទី៩ និងកម្មវិធីសិក្សាផ្នែកបំណិនជីវិត អនុម័តឯកសារការផ្តល់ប្រឹក្សាអាជីព និងព័ត៌មានសិក្សាជំនាញកែលម្អកម្មវិធីសិក្សាឱ្យស្របនឹងតម្រូវការទីផ្សារការងារលើជំនាញមេកានិច អគ្គិសនី អេឡិចត្រូនិច

ក្បេត្រសាស្ត្រ និងបសុវប្បកម្ម ពង្រីកវិទ្យាល័យចំណេះដឹង និងបច្ចេកទេសថ្មី៣)

**ទី១៤: ការបង្កើតសាលាជំនាន់ថ្មី** (អនុវត្តគោលនយោបាយស្ដីពីសាលាជំនាន់ថ្មី ដំណើរការសាលារៀនជំនាន់ថ្មីវិទ្យល័យស៊ីសុវត្ថិ)

**ទី១៥: ការរៀបចំគន្លងអាជីព និងការបណ្ដុះបណ្ដាលនាយកសាលា** (អភិវឌ្ឍឯកសារទស្សនៈទានស្ដីពីគន្លងអាជីពគ្រូបង្រៀន រៀបចំសៀវភៅមគ្គុទេសក៍នាយកសាលា បំប៉ននាយកសាលាគ្រប់កម្រិតលើការងារអធិការកិច្ច គ្រប់គ្រង ដឹកនាំ និងប្រព័ន្ធអធិការកិច្ចអប់រំ រៀបចំប្រព័ន្ធសន្សំក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈនាយកសាលា)

ក្រសួងបានអនុម័តដាក់ចេញវិធានការកំណែទម្រង់១៥ចំណុច ដោយឈរលើមូលដ្ឋាន **សសរស្តម្ភ៥ ដើម្បីធានាគុណភាពអប់រំគឺៈ**

**ទី១: កំណែទម្រង់គុណវុឌ្ឍិគ្រូបង្រៀន** (បណ្ដុះបណ្ដាលគ្រូមូលដ្ឋានទៅជាគ្រូបង្រៀនកម្រិតឧត្ដម កំពុងអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទៅជាវិទ្យាស្ថានគរុកោសល្យ អនុម័តស្តង់ដារគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ និងស្តង់ដារនាយកសាលា កំពុងរៀបចំស្តង់ដារគ្រូបង្រៀន និងគន្លងអាជីពគ្រូបង្រៀន)

**ទី២: ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថាន** (អនុម័ត និងផ្សព្វផ្សាយក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសដាក់ដំណើរការសាលាជំនាន់ថ្មី មានវិទ្យាល័យស៊ីសុវត្ថិ អនុម័តនិងផ្សព្វផ្សាយឱ្យប្រើប្រាស់គោលការណ៍អនុវត្តលក្ខខណ្ឌអប្បរមាស្ដីពី ចលនាប្រឡងប្រណាំងសាលារៀនស្អាត សាងសង់អគារមត្តេយ្យសិក្សាសហគមន៍ សាលាមត្តេយ្យសិក្សាធនធាន ផ្ទះគ្រូស្នាក់នៅ និងអគារការិយាល័យអប់រំ ជួសជុល និងការកែលម្អមណ្ឌលប្រឡង)

**ទី៣: ការដាក់ឱ្យអនុវត្តអធិការកិច្ច** (អនុម័តបញ្ញត្តិធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ រៀបចំឧបករណ៍សម្រាប់អធិការកិច្ច សៀវភៅជំនួយស្មារតីអធិការកិច្ច និងទម្រង់របាយការណ៍អធិការកិច្ច បណ្ដុះបណ្ដាលអធិការកិច្ច)

**ទី៤: ការពង្រឹងវាយតម្លៃការសិក្សា** (បំប៉នមន្ត្រីជំនាញអំពីការងារតេស្តវាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ធ្វើតេស្តល្បឿនអំណាន ធ្វើតេស្តវាយតម្លៃកម្រិតតំបន់ថ្នាក់បឋមសិក្សា និងរៀបចំតេស្តវាយតម្លៃកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ)

**ទី៥: គុណភាពឧត្តមសិក្សា** (កែលម្អនីតិវិធី និងដំណើរការទទួលស្គាល់គុណភាពអប់រំ ព្រាងស្តង់ដារទទួលស្គាល់គុណភាពអប់រំកម្រិតបណ្ឌិត ពង្រឹង និងពង្រីកការអប់រំមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ត្រៀមបង្កើតគណៈកម្មាធិការវិទ្យាសាស្ត្រកម្ពុជាសម្រាប់ការស្រាវជ្រាវ និងបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងបង្កើតសាលាថ្នាក់បណ្ឌិត។)

កម្ពុជាបាននឹងកំពុងខិតខំប្រឹងប្រែងបន្ថែមទៀតលើការបង្កើនប្រសិទ្ធភាព និងគុណភាពអប់រំក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដើម្បី "ធានាឱ្យការអប់រំ មានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាឆ្នាំ២០៣០ ហើយក្រសួងបាននឹងកំពុងរៀបចំមូលដ្ឋាននីយកម្មគោលដៅអប់រំថ្មីនេះ តាមរយៈការរៀបចំចក្ខុវិស័យ អប់រំកម្ពុជានាឆ្នាំ២០៣០ ជាមួយនិងការអភិវឌ្ឍធនធានមនុស្សស្របទៅនឹង "គោលដៅអភិវឌ្ឍវិស័យ ឧស្សាហកម្មឆ្នាំ២០២៥" ដែលជាជំហានថ្មីមួយទៀតក្នុងការតម្រង់ទិសការអភិវឌ្ឍកម្ពុជា ឆ្លើយតបទៅនឹងមហិច្ឆតាកម្ពុជាក្នុងការប្រែក្លាយខ្លួនទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងមានចំណូលខ្ពស់នាឆ្នាំ២០៥០***(កំណែទម្រង់១៥ចំណុច ឆ្នាំ២០១៦ ឯកសារអប់រំខ្មែរ)***។

## ២.៥.អំពីការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬការប្រឡងមធ្យមសិក្សាកម្រិត២ ឬហៅថាការប្រឡងបាក់ឌុប ត្រូវបានធ្វើឡើងជារៀងរាល់ចុងឆ្នាំសិក្សានីមួយៗ ក្នុងគោលបំណងវាស់ស្ទង់ចំណេះដឹងរបស់សិស្ស ដែលបានសិក្សាអស់រយៈពេល១២ឆ្នាំកន្លងមក និងអាចឱ្យសិស្សមានសមត្ថភាពដើម្បីបន្តការសិក្សានៅសាកលវិទ្យាល័យ ឬអាចរកការងារផ្សេងៗធ្វើនៅក្នុងសង្គម។ ក្រោយពីមានការធ្វើកំណែទម្រង់ លើការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនាឆ្នាំ២០១៤

កន្លងមក យើងឃើញថាការអប់រំត្រូវបានមហាជន ឬសាធារណៈមតិមានការចាប់អារម្មណ៍ ហើយសិស្សានុសិស្សមានការប្រុងប្រយ័ត្នក្នុងការងាររៀនសូត្ររបស់ខ្លួនខ្លាំងជាងមុន។

បច្ចុប្បន្នការកែទម្រង់លើវិស័យអប់រំ បានធ្វើឱ្យមានទំនាក់ទំនងល្អពីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់ស្រុក សាលារៀន គ្រួសារ សហគមន៍ និងសង្គម ព្រមទាំងបង្កើតឱ្យមានការសហការគ្នាបានយ៉ាងល្អប្រសើរផងដែរ។ ដូច្នេះ យើងសង្កេតឃើញថា កត្តាដែលជំរុញឱ្យការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិរបស់សិស្សទទួលបានលទ្ធផលល្អគឺអាស្រ័យលើះ

**១.គុណភាពនាយកសាលា**

**២.គុណភាពកម្មវិធីសិក្សា**

**៣.គុណភាពគ្រូ**

**៤.គុណភាពសិស្ស**

**៥.ការជំរុញ និងលើកទឹកចិត្តពីមាតាបិតា/អាណាព្យាបាលសិស្ស**

**៦.អង្គភាពប្រឆាំងអំពើពុករលួយ (ACU)**

### ២.៤.១.គុណភាពនាយកសាលា

ជាមនុស្សស្មោះត្រង់ និងលះបង់

មានចំណេះដឹងខ្ពស់ និងមានបទពិសោធន៍ច្រើនក្នុងការងារអប់រំ

ជាមនុស្សដែលពូកែខាងទំនាក់ទំនង

ជាមនុស្សដែលពូកែខាងដោះស្រាយបញ្ហាផ្សេងៗ

- **គុណភាពការដឹកនាំ និងគ្រប់គ្រង**

នាយកសាលាដែលមានការដឹកនាំ និងគ្រប់គ្រងល្អត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោមះ

- ចងចាំជានិច្ចថាគ្រូបង្រៀនជាអ្នកធ្វើឱ្យសាលាមានគុណភាព មិនមែនកម្មវិធីសិក្សានោះទេ ឆ្លៀតឱកាសក្នុងការស្វែងរកគ្រូល្អ (Best teacher) ពីខាងក្រៅ និងបន្តថែរក្សាគ្រូល្អដែលមានស្រាប់

បន្តប្រោះយកចេញនូវគំនិតអវិជ្ជមាន ហើយចែករំលែកនូវការគិតបែបវិជ្ជមាន

ទទួលខុសត្រូវចំពោះសកម្មភាពការងាររបស់ខ្លួន និងផ្នែកផ្សេងៗទៀតនៅក្នុងសាលារៀនទាំងមូល

ផ្តោតជាសំខាន់ទៅលើបញ្ហាក្នុងការសិក្សារបស់សិស្សដោយមានទស្សនវិស័យស្តង់ដារ

មានភក្តីភាព (Loyalty) ចំពោះសិស្ស គ្រូបង្រៀន និងសាលា ដោយមានក្តីរំពឹងថាភាពស្មោះត្រង់នឹងទទួលបានមកវិញ

ក្រោយពេលធ្វើការសម្រេចចិត្ត រួចបន្តសួរខ្លួនឯងថា តើមានទំនុកចិត្តទៅលើបុគ្គលិកណាខ្លាំងជាង ហើយត្រូវចាត់ទុកបុគ្គលិកទាំងអស់ជាមនុស្សល្អដូចគ្នា

រកវិធីសាស្ត្រជាជំហានៗ ដើម្បីកែច្នៃបុគ្គលិកឱ្យល្អប្រសើរ(Improve) និងជម្រុះចោល (Remove) បុគ្គលិកដែលមានភាពអវិជ្ជមាន និងគ្មានប្រសិទ្ធភាពការងារ

មានភាពច្បាស់លាស់ចំពោះបុគ្គលិក ដោយអាចកំណត់បានថា គេជានរណា? ហើយគេធ្វើអ្វីខ្លះ?

បង្កើតបរិយាកាសវិជ្ជមាននៅក្នុងសាលា ដោយមានការគោរព និងឱ្យតម្លៃគ្នា ជាពិសេសយល់ច្បាស់ នៃឥទ្ធិពលនៃការសរសើរ និងលើកទឹកចិត្ត

គិតដោយប្រុងប្រយ័ត្ន ក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រពង្រឹងគុណភាពគ្រូ ដើម្បីឆ្លើយតបទៅនឹងគោលបំណងរបស់សាលា

មានគំនិតក្នុងការផ្លាស់ប្តូរ ឬ/និងយល់អំពីកម្លាំងនៃការផ្លាស់ប្តូរ

ដឹងអំពីពេលវេលា ដែលផ្តោតអារម្មណ៍ទៅលើអាកប្បកិរិយារបស់បុគ្គលិក មុនពេលមានជំនឿ

ខំប្រឹងធ្វើការ និងមានការលះបង់ខ្ពស់ក្នុងការរក្សានូវទំនាក់ទំនងល្អ ដើម្បីចៀសវាងការប៉ះពាល់ផ្លូវអារម្មណ៍ ឬបែកបាក់ណាមួយដែលអាចកើតឡើង

បង្កើតនូវការចង់បាន(Expectation) ដ៏ច្បាស់លាស់មួយនៅពេលដែលចាប់ផ្តើមឆ្នាំសិក្សាថ្មី និងធ្វើការតាមដានអំពីដំណើរការវិវត្តជាបន្តបន្ទាប់*(ប្រភព Facebook ក្រសួង អយក)*។

### ២.៩.២.គុណភាពកម្មវិធីសិក្សា

សមស្របតាមសមត្ថភាពជាក់ស្តែង

ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រទេស (បរិបទសង្គម)

ទំនើបកម្មកម្មវិធីសិក្សា (ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា)

គុណភាពសៀវភៅសិក្សាគោល

គុណភាពបណ្ណាល័យ

គុណភាពសម្ភារៀន និងបង្រៀន

គុណភាពបន្ទប់ពិសោធន៍

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣ ផ្តល់អាទិភាពទៅលើចំណុចសំខាន់ៗ ដូចតទៅៈ

ផែនការស្តីពីការអភិវឌ្ឍមធ្យមសិក្សា (រួមមានសៀវភៅប្រតិបត្តិ សម្រាប់ដំណើរការធនធានមនុស្ស នៅមធ្យមសិក្សា និងគោលនយោបាយស្តីពីសាលាកុមារមេត្រី នៅមធ្យមសិក្សា និងការកែលម្អកម្មវិធីសិក្សា។)

ប្រព័ន្ធវិក្រឹតការគ្រូបង្រៀន (មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ)

កម្មវិធីបំណិនជីវិត បច្ចេកវិទ្យាព័ត៌មាន និងទេសចរណ៍

បង្កើនឱ្យមានការចូលរៀន និងគុណភាពអប់រំ

កាត់បន្ថយអត្រាថយចុះនៃសិស្ស និងអត្រាធ្លាក់

ការលើកទឹកចិត្ត ដោយផ្តល់អាហារូបករណ៍ ឬមេដាយ

### ២.៩.៣.គុណភាពគ្រូ

គ្រូបង្រៀនរៀនត្រូវមានគុណវុឌ្ឍិដូចខាងក្រោមៈ

1. ចំណេះដឹងជំនាញឯកទេស (Knowledge of Specialization)

2. ចំណេះដឹងគរុកោសល្យ (Knowledge of Pedagogy)
3. ចំណេះដឹងផ្នែកបច្ចេកវិទ្យាអប់រំ (Knowledge of Technology in Education)
4. ចំណេះដឹងភាសាបរទេស (Knowledge of a Foreign Language FL)
5. សីលធម៌វិជ្ជាជីវៈ (Knowledge of Professional Ethics)
6. បុគ្គលិកលក្ខណៈល្អ (Personalities)

- **គ្រូបង្រៀនត្រូវមានគណនេយ្យភាព(Accountabilities)ដូចខាងក្រោម៖**

  វិធីសាស្ត្របង្រៀន

  ទំនាក់ទំនង

  ការវាយតម្លៃ

  វិន័យការងារ

  ការគ្រប់គ្រងថ្នាក់រៀន

  ស្មារតី (មនសិការការងារ)

  លធម៌វិជ្ជាជីវៈ

**២.៨.៤.គុណភាពសិស្ស**

ក្នុងនាមជាសិស្សានុសិស្សត្រូវមានទំនួលខុសត្រូវដូចខាងក្រោម៖

មានវិន័យក្នុងការសិក្សា

ចេះចែករំលែង

សាមគ្គីភាព

មានសីលធម៌រស់នៅល្អ

ប្រឹងប្រែងរៀនសូត្រ

**២.៨.៥.ការជំរុញ និងលើកទឹកចិត្តពីមាតាបិតា/អាណាព្យាបាលសិស្ស**

មាតិបិតា ឬអាណាព្យាបាលសិស្សត្រូវមានទំនួលខុសត្រូវដូចខាងក្រោម៖

តាមដានការសិក្សារបស់កូនជាប្រចាំ

ចូលរួមលើកកម្ពស់ការអប់រំ

ប្រឹក្សាការអភិវឌ្ឍសាលារៀន

ជួយរំរុញ និងលើកទឹកចិត្តដល់កូនក្នុងការសិក្សារៀនសូត្រ

**២.៥.៦.អង្គភាពប្រឆាំងអំពើពុករលួយ (ACU)**

មានតួនាទី និងទំនួលខុសត្រូវដូចខាងក្រោម៖

ពិនិត្យតាមដាននូវរាល់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ចូលរួមសហការណ៍ជាមួយក្រសួងអប់រំ ដើម្បីឱ្យការប្រឡងមានលក្ខណៈកាន់តែល្អប្រសើរឡើង

ពិនិត្យ និងសរសេររបាយការណ៍នូវរាល់ភាពមិនប្រក្រតីនានា នៃការប្រឡងក្នុងឆ្នាំសិក្សានីមួយៗ

ប្រជុំជាមួយក្រសួងអប់រំ និងភាគីពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានឡើង។

## ២.៦.ប្រសិទ្ធភាព នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ក្រសួងអប់រំ បានដាក់ចេញនូវគោលការណ៍សំខាន់ៗចំនួន៤ ដើម្បីជានាឱ្យមានប្រសិទ្ធភាពក្នុងពេលប្រឡងគឺ៖

**ទី១៖ គោលការណ៍ច្បាប់** គឺនៅគ្រប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទាំងអស់ត្រូវឈរលើគោលការណ៍ច្បាប់ជាធំ ដោយបេក្ខជនម្នាក់ៗត្រូវគោរពច្បាប់និងបទបញ្ជានៅពេលប្រឡង ដោយមិនតម្រូវឱ្យយកសំណៅឯកសារផ្សេងៗចូលក្នុងមណ្ឌលប្រឡង និងត្រូវស្លៀកសម្លៀកបំពាក់សមរម្យជាដើម។

**ទី២៖ គោលការណ៍យុត្តិធម៌** គឺបេក្ខជនម្នាក់ៗ ទទួលបានយុត្តិនៅក្នុងការប្រឡងដោយបញ្ចេញនូវសមត្ថភាពពិតប្រាកដរបស់ខ្លួន ពោលគឺ "**អ្នកចេះ គឺជាប់**"។

**ទី៣៖ គោលការណ៍តម្លាភាព** គឺបេក្ខជនម្នាក់ៗ ទទួលបានសិទ្ធិស្មើៗគ្នាក្នុងពេលប្រឡង ដោយតម្លាភាព មិនមាននរណាលួចចម្លងគ្នា ឬសរសេរកិច្ចការជំនួសគ្នាបាននោះឡើយ នៅក្នុងមណ្ឌលប្រឡង។

**ទី៤៖ លទ្ធផលទទួលយកបាន** ជាមួយគ្នានេះដែរលទ្ធផលប្រឡងគឺត្រូវបានសាធារណជន ទទួលស្គាល់ច្រើនចំពោះលទ្ធផលកន្លងមកដោយក្រសួងជាអ្នកទទួលខុសដោយត្រូវផ្សាល់ ចំពោះមុខសាធារណជន ក៏ដូចជាមាតាបិតាសិស្សផងដែរ។

## ២.៧.បទប្បញ្ញត្តិចំពោះបេក្ខជន និងបុគ្គលិកអប់រំ សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

❖ **បុគ្គលដែលមានសិទ្ធិយកចូល និងប្រើប្រាស់** (នូវទូរស័ព្ទដៃ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទក្នុងមណ្ឌលសំណេរ) រួមមាន៖

- គណៈមេប្រយោគទូទាំងប្រទេស
- ប្រធានអប្បមាទទូទាំងប្រទេសប្រចាំមណ្ឌល
- ប្រធានមណ្ឌល
- ប្រធានសន្តិសុខប្រចាំមណ្ឌល

❖ **បុគ្គលដែលមិនអនុញ្ញាតឱ្យយកចូល និងប្រើប្រាស់** (នូវទូរស័ព្ទដៃ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទក្នុងមណ្ឌលសំណេរ) រួមមាន៖

- បេក្ខជនប្រឡង
- អនុប្រធាន សមាជិកអប្បមាទ និងជំនួយការអប្បមាទ
- អនុប្រធានមណ្ឌល
- គណៈកម្មការកណ្តាល អ្នកត្រួតពិនិត្យអគារ
- អនុរក្ស សមាជិកសន្តិសុខ និងបុគ្គលិកសុខាភិបាលប្រចាំមណ្ឌល

❖ **ចំពោះបេក្ខជនក្នុងថ្ងៃប្រឡងត្រូវអនុវត្តដូចខាងក្រោម៖**

- បេក្ខជនទាំងអស់ត្រូវស្លៀកពាក់ **ឯកសណ្ឋានសិស្ស** ដោយយកមកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតសម្គាល់ខ្លួន សិស្សថ្នាក់ទី១២ និងសលាកបត្រឯកត្តជន។
- បេក្ខជនទាំងអស់ ត្រូវមកដល់បន្ទប់ប្រឡង
    - ➢ ពេលព្រឹក ៖ ម៉ោង ៦:០០ នាទី
    - ➢ ពេលរសៀល ៖ ម៉ោង ១៣:០០ នាទី
- មិនអនុញ្ញាតឱ្យបេក្ខជន យកទូរស័ព្ទ ឬសំណៅឯកសារផ្សេងៗ និងសម្ភារៈហាមឃាត់ចូលក្នុងបន្ទប់ប្រឡងឡើយ
- បេក្ខជនណា ដែលប្រព្រឹត្តខុស ពីបទប្បញ្ញត្តិនៃការប្រឡង នឹងត្រូវទទួលទោសតាមកម្រិតវិន័យ។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនិក្ខេបបទ **"ប្រសិទ្ធភាព នៃការធ្វើកំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិ ពីឆ្នាំ២០១៧-២០១៨"** អ្នកសិក្សាស្រាវជ្រាវយកវិធីសាស្ត្របែប បរិមាណវិស័យ និងគុណវិស័យដោយចង់បង្ហាញអំពី៖

១).បង្កើនទំនុកចិត្តដល់សាធារណជន មាតាបិតាសិស្សឱ្យមានភាពជឿជាក់លើការប្រឡង ក៏ដូចជាបានលើកកម្ពស់វិស័យអប់រំ

២).ធ្វើឱ្យសាធារណជនទទួលយកបានអំពីលទ្ធផល និងប្រសិទ្ធភាព នៃការប្រឡងសញ្ញាបត្រតាមរយៈកំណែទម្រង់នេះ

៣).យល់បានពីបញ្ហាលុបបំបាត់អំពើពុករលួយផ្សេងៗ តាមរយៈកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា

## ៣.១.ការជ្រើសរើសភាគសំណាក

ដោយយល់ឃើញពីកម្រិតយល់ដឹងរបស់ប្រជាជន ក៏ដូចជាជីវភាពរស់នៅរបស់សិស្សានុសិស្សនៃក្រុមគោលដៅស្រាវជ្រាវ។ ហេតុនេះហើយ ភាគសំណាកសម្រាប់ការសិក្សាស្រាវជ្រាវមួយនេះ បានកំណត់យកសាលាចំនួន០៤ ដែលស្ថិតនៅស្រុកផ្សេងៗគ្នាចំនួនបីនៅក្នុងខេត្តកំពត គឺ(១)ស្រុកដងទង់ មាន**វិទ្យាល័យអង្គ រមាស** និង**វិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ដងទង់** (២)ស្រុកឈូក មាន**វិទ្យាល័យ ហ៊ុន សែន ឈូក** និង(៣)ស្រុកជុំគីរី មាន**វិទ្យាល័យ ហ៊ុន សែន អង្គចក**។ ហេតុផល ដែលជ្រើសរើសយកសំណាកចំនួន០៣ស្រុកនេះ គឺសំដៅយកប្រភេទមូលដ្ឋាន ដែលមានកម្រិតជីវភាពសេដ្ឋកិច្ចសិក្សាខុសៗគ្នា ដើម្បីធ្វើការប្រៀបធៀបគ្នាឱ្យដឹងពីទស្សនៈនៃអ្នកពាក់ព័ន្ធនានា ហើយក៏ដើម្បីធ្វើឱ្យការស្រាវជ្រាវកាន់តែមានលក្ខណៈស៊ីជម្រៅថែមទៀត។

សិស្សសរុបចំនួន៨០នាក់ ដែលជ្រើសចេញពីសាលាគោលដៅចំនួន០៤ ដោយជ្រើសរើសសិស្សប្រឡងទី១២ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ និងឆ្នាំសិក្សា២០១៨-២០១៩ ដោយក្នុងនៅ

សាលានីមួយៗ គឺយកសិស្សចំនួន២០នាក់ ការជ្រើសរើសសិស្សទាំងនេះមកធ្វើជាភាគសំណាក គឺពីព្រោះតែចង់ដឹង ពីទស្សនៈរៀងៗខ្លួនរបស់បេក្ខជន ដែលបានប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិកន្លងមក និងសិស្សដែលកំពុងត្រៀមលក្ខណៈក្នុងការប្រឡងតែប៉ុណ្ណោះ។ ចំពោះវិធីជ្រើសរើសសិស្សគឺយកចេញពីបញ្ជីឈ្មោះសិស្សតាមថ្នាក់នីមួយៗ មកចាប់យកដោយចៃដន្យ ដោយធ្វើយ៉ាងណាឱ្យបានគ្រប់ចំនួន ដើម្បីធ្វើការសម្ភាសន៍។ ចំពោះលោកគ្រូ អ្នកគ្រូ ដែលបង្រៀនថ្នាក់ទី១២ ដែលធ្លាប់បានចូលរួមកែ និងលោកគ្រូ អ្នកគ្រូ ដែលធ្លាប់បានចេញជាអនុរក្សក្នុងពេលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងជាគណៈកម្មការក្នុងកិច្ចការប្រឡង សរុបចំនួន៤០នាក់ ដោយក្នុងសាលានីមួយៗកំណត់យក១០នាក់។ ចំណែកគណៈនាយក និងនាយករងសរុបចំនួន១២នាក់ ដោយសាលានីមួយៗកំណត់យក០៣នាក់ ហើយជ្រើសរើសយកតែអ្នកដែលបានចូលរួមប្រឡងថ្នាក់ជាតិ។ រីឯការជ្រើសរើសមាតាបិតា ឬអាណាព្យាបាលសិស្សមកធ្វើភាគសំណាកគឺអ្នកសិក្សាស្រាវជ្រាវកំណត់យកសរុបចំនួន២០នាក់ ដោយមួយសាលាជ្រើសយក ០៥នាក់ ពោលគឺមាតាបិតា ឬអាណាព្យាបាលសិស្សដែលបានប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិកន្លងទៅ និងមាតាបិតា ឬអាណាព្យាបាលសិស្ស ដែលបានប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំសិក្សា២០១៨-២០១៩នេះ។

**តារាងបែងចែកចំនួនភាគសំណាកតាមគោលដៅសាលាក្នុងខេត្តកំពត**

| ល.រ | អ្នកឆ្លើយតប (សំណាក) | វិ.អង្គ រមាស ស្រុកដងទង់ | វិ.បបហស ដងទង់ ស្រុកដងទង់ | វិ.ហ៊ុន សែនឈូក ស្រុកឈូក | វិ.ហ៊ុន សែន អង្គចក ស្រុកជុំគីរី |
|---|---|---|---|---|---|
| ១ | គណៈនាយក | ០៣ | ០៣ | ០៣ | ០៣ |
| ២ | លោកគ្រូ អ្នកគ្រូ | ១០ | ១០ | ១០ | ១០ |
| ៣ | សិស្សទី១២ចាស់ | ១០ | ១០ | ១០ | ១០ |
| ៤ | សិស្សទី១២ ថ្មី | ១០ | ១០ | ១០ | ១០ |
| ៥ | មាតាបិតាសិស្ស | ០៥ | ០៥ | ០៥ | ០៥ |
| **សរុបរួម** | | **១៥២ នាក់** | | | |

## ៣.២.ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវវិញ អ្នកស្រាវជ្រាវបានរៀបចំបង្កើតកម្រងសំណួរចំនួនពីរប្រភេទគឺ (១)បែបបរិមាណវិស័យ និង(២)បែបគុណវិស័យ ក្នុងការចុះប្រមូលទិន្នន័យ។ កម្រងសំណួរទាំងនេះ ត្រូវបានប្រើប្រាស់ក្នុងការសម្ភាសន៍ចំពោះ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ សិស្ស និងមាតាបិតាសិស្ស ដែលជាក្រុមគោលដៅក្នុងការប្រមូលព័ត៌មាន។

**តារាងរយៈពេល នៃការឆ្លើយតបទៅនឹងកម្រងសំណួរស្រាវជ្រាវ**

| ក្រុមគោលដៅ | គណៈនាយក | លោកគ្រូ អ្នកគ្រូ | សិស្ស | មាតាបិតាសិស្ស |
|---|---|---|---|---|
| **រយៈពេល** | ៣០នាទី/១នាក់ | ៣០នាទី/១នាក់ | ៣០នាទី/១នាក់ | ២០នាទី/១នាក់ |

ចំពោះកម្រងសំណួរទាំងនេះ ត្រូវបានអ្នកស្រាវជ្រាវរៀបចំឡើង ដោយមានការណែនាំពិភាក្សា និងផ្តល់យោបល់ជាប្រចាំពីសាស្ត្រាចារ្យដឹកនាំ និងសាស្ត្រាចារ្យដឹកនាំរងក៏ដូចជាសាស្ត្រាចារ្យផ្សេងៗទៀត។ បន្ទាប់ពីមានការពិគ្រោះយោបល់ជាច្រើនលើកច្រើនគ្រា និងមានការណែនាំកែតម្រូវពីសាស្ត្រាចារ្យណែនាំរួចមក ឧបករណ៍នេះត្រូវបានត្រួតពិនិត្យ និងកែលម្អបញ្ចប់។ មុនពេលសិក្សាស្រាវជ្រាវជាក់ស្តែង អ្នកស្រាវជ្រាវបានជួបជាមួយសិស្សានុសិស្ស លោកគ្រូអ្នកគ្រូមួយចំនួន ក៏ដូចជាគណៈគ្រប់គ្រងសាលាដើម្បីសុំយោបល់កែលម្អឧបករណ៍ស្រាវជ្រាវនេះ បន្ទាប់មកទៀត បានសាកល្បងប្រើប្រាស់ឧបករណ៍នេះ ជាមួយក្រុមគោលដៅជាច្រើនទៀត ដើម្បីពិនិត្យមើលថា តើវាសមស្របអាចនឹងប្រើប្រាស់សម្រាប់ការសិក្សាស្រាវជ្រាវពិតប្រាកដបានហើយឬនៅ។

### ៣.២.១.វិធីបង្កើតកម្រងសំណួរ

ការបង្កើតកម្រងសំណួរសម្ភាសន៍ គឺយើងប្រើប្រាស់ឯកសារពាក់ព័ន្ធរបស់ក្រសួង មន្ទីរការិយាល័យមធ្យមសិក្សា ការិយាល័យប្រឡងជាភាសាខ្មែរ និងការស្រាវជ្រាវឯកសារបរទេសដើម្បីប្រៀបធៀបខ្លឹមសារ ដែលពាក់ព័ន្ធទៅនឹងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

**៣.២.២.លក្ខណៈទម្រង់កម្រងសំណួរសម្ភាសន៍**

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

**ផ្នែកទី២៖ អំពីការសិក្សា និងកិច្ចការប្រឡង**

**ផ្នែកទី៣៖ ការបញ្ចេញមតិយោបល់** ការយល់ឃើញពីនីតិវិធីនៃការរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងប្រសិទ្ធភាពនៃកំណែទម្រង់ការប្រឡង បញ្ហាប្រឈម និងអំពីសំណូមពរផ្សេងៗ។

## ៣.៣.នីតិវិធី និងដំណើរការប្រមូលទិន្នន័យ

ក្រៅពីការរំលឹកទ្រឹស្តី និងការសិក្សាទៅលើឯកសារដែលមានស្រាប់ ហើយក៏បានចុះសិក្សាជាក់ស្តែងនៅតាមសាលាគោលដៅចំនួន០៤ គឺសាលាវិទ្យាល័យ ហ៊ុន សែន ឈូក (ស្រុកឈូក) វិទ្យាល័យ ហ៊ុន សែន អង្គចក (ស្រុកជុំគីរី) វិទ្យាល័យអង្គ រមាស និងវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ដងទង់ (ស្រុកដងទង់) ដែលស្ថិតនៅក្នុងខេត្តកំពត ដើម្បីប្រមូលទិន្នន័យជាបឋម សម្រាប់ការសិក្សាស្រាវជ្រាវនេះ។ ការចុះសិក្សាតាមទីកន្លែងដែលបានជ្រើសរើសនេះ មានរយៈពេល**៥១ថ្ងៃ** គឺចាប់ពី**ថ្ងៃទី១០ ខែមិថុនា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩**។ ជាដំបូង អ្នកស្រាវជ្រាវបានស្នើសុំអនុញ្ញាតពីវិទ្យាស្ថានជាតិអប់រំ ដើម្បីអាចទៅចុះប្រមូលទិន្នន័យពីសាលានីមួយៗ។ បន្ទាប់មកបានចុះជួបជាមួយនឹងមន្ត្រីនៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពត ដើម្បីសាកសួរព័ត៌មានបន្ថែមអំពីទីតាំង ដែលបានកំណត់សម្រាប់ធ្វើការស្រាវជ្រាវនេះ។ បន្ទាប់ពីបាន កំណត់ទីកន្លែងសម្រាប់ស្រាវជ្រាវរួចហើយ យើងក៏បានជួបជាមួយមន្ត្រីការិយាល័យ យុវជន និងកីឡាស្រុក ដោយបានរៀបចំចុះទៅមើលសាលា ដែលបានជ្រើសរើសសម្រាប់ការស្រាវជ្រាវនេះ។ បន្ទាប់មកទៀត យើងក៏បានជួបនឹងនាយកសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅតាមសាលានីមួយៗ ដើម្បីជម្រាបពួកគាត់ពីគោលបំណងនៃការចុះសិក្សានេះ។ អ្នកសិក្សាស្រាវជ្រាវ ក៏បានស្នើសុំនាយក និងលោកគ្រូ អ្នកគ្រូឱ្យជួយសម្របសម្រួលក្នុងដំណើរការ នៃការស្រាវជ្រាវនេះ ក៏ដូចជាការជួយប្រមូលសិស្សទី១២ ទាំងថ្នាក់សង្គម និងវិទ្យាសាស្ត្រឱ្យមកចូលរួមក្នុងការពន្យល់ណែនាំពីគោលបំណងនៃការស្រាវជ្រាវនេះផងដែរ។ សិស្សទីនេះរួមមាន សិស្សថ្នាក់ទី១២ចាស់

(ធ្លាក់ និងជាប់) ដែលបានប្រឡងមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំសិក្សា២០១៧-២០១៨ កន្លងមក និងសិស្សថ្នាក់ទី១២ថ្មី ដែលកំពុងសិក្សាត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នាឆ្នាំសិក្សា២០១៨-២០១៩ នេះផងដែរ។

ការសម្ភាសន៍នេះ មានរយៈពេល៣០នាទី ដោយឡែកចំពោះការសម្ភាសន៍មានរយៈពេលចំនួន១០នាទីសម្រាប់សិស្ស០១នាក់ ហើយធ្វើឡើងបន្ទាប់ពីសិស្សបានបំពេញកម្រងសំណួររួចរាល់។ ក្រោយពី សិស្សទាំងអស់បានបំពេញចម្លើយរួចរាល់ យើងក៏បានប្រមូលសន្លឹកកិច្ចការទាំងអស់ ដែលមានចម្លើយរបស់សិស្សសម្រាប់យកមកវិភាគទិន្នន័យ។ លើសពីនេះទៅទៀត យើងបានស្នើសុំដល់គណៈនាយក និងលោកគ្រូ អ្នកគ្រូ ដើម្បីបំពេញកម្រងសំណួរ ដែលមានរយៈពេល៣០នាទី និងធ្វើការសម្ភាសន៍រយៈពេល១០នាទី ក្នុង០១នាក់បន្ថែមទៀតក្នុងការប្រមូលព័ត៌មាន។ មិនតែប៉ុណ្ណោះ អ្នកសិក្សាស្រាវជ្រាវ ក៏បានទំនាក់ទំនងទៅអាណាព្យាបាលសិស្សចំនួន០៥នាក់ក្នុងមួយសាលា ដើម្បីធ្វើការសម្ភាសន៍ពាក់ព័ន្ធនឹង ការយល់ឃើញចំពោះកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដែលប្រព្រឹត្តទៅនាឆ្នាំកន្លងមក និងកំពុងបន្តអនុវត្តក្នុងឆ្នាំសិក្សា ២០១៨-២០១៩ នេះផងដែរ។ ធ្វើយ៉ាងនេះក្នុងគោលបំណងប្រមូលទស្សនៈ ឬការយល់ឃើញផ្សេងៗគ្នា ដែលបានមកពីគ្រប់មជ្ឈដ្ឋានជុំវិញការធ្វើកំណែទម្រង់ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ របស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាការធ្វើការសិក្សាស្រាវជ្រាវមានឱ្យលក្ខណៈស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយថែមទៀត។

ការសម្ភាសន៍ សិស្ស លោកគ្រូ អ្នកគ្រូ គណៈនាយក និងមាតាបិតា ឬអាណាព្យាបាលសិស្សត្រូវរក្សាការសម្ងាត់ និងក្រមសីលធម៌ហើយជាទឡ្ហីករណ៍ ដែលអាចឱ្យអ្នកស្រាវជ្រាវប្រមូលបានព័ត៌មានដ៏មានសារប្រយោជន៍ ជាពិសេសអាចប្រមូលបានទិន្នន័យដំបូងដ៏មានសារៈសំខាន់សម្រាប់ការសិក្សា ស្វែងយល់បន្ថែមពីការរៀបចំ និងដំណើរការប្រព្រឹត្តទៅ នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងដើម្បីវាស់វែងពីប្រសិទ្ធភាព នៃការអនុវត្តគោលនយោបាយកំណែទម្រង់ការប្រឡងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលឆ្លុះបញ្ចាំងឱ្យគេមើលឃើញកាន់តែច្បាស់នូវចំណុចខ្លាំង និងបញ្ហាប្រឈម ដែលបានកើតមានឡើងក្នុងពេលកំពុងអនុវត្ត

ការងាររបស់មន្ត្រីអប់រំនៅថ្នាក់មូលដ្ឋាន ក្រោមគោលនយោបាយវិមជ្ឈការ នៅថ្នាក់ក្រោមជាតិរបស់ក្រសួងអប់រំ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា ដែលបានដាក់ចេញនាពេលកន្លងមក។

## ៣.៤.ការវិភាគទិន្នន័យ

អ្នកស្រាវជ្រាវ នឹងវិភាគទិន្នន័យលើចម្លើយដែលប្រមូលបានពីការសម្ភាសន៍កម្រងសំណួរជាមួយសិស្ស គ្រូ គណៈនាយក និងមាតាបិតា អាណាព្យាបាលសិស្ស ដើម្បីធ្វើឱ្យព័ត៌មានដែលទទួលបានកាន់តែមានភាពច្បាស់លាស់ថែមទៀត។ ការវិភាគចម្លើយ នូវរាល់កម្រងសំណួរទាំងអស់ធ្វើឡើងតាមចំណាងជើងធំៗ បន្ទាប់មកចំណាងជើងតូចៗ ដោយរៀបរាប់ចម្លើយតាមប្រភេទដូចគ្នា និងខុសគ្នារួចទាញរកសេចក្តីសន្និដ្ឋាន។ រីឯព័ត៌មានផ្សេងៗទៀត ដែលបានផ្តល់ឱ្យក្នុងពេលសម្ភាសន៍ជាមួយភាគសំណាក ក៏ជាព័ត៌មានសំខាន់សម្រាប់គាំទ្រដល់លទ្ធផលនៃការស្រាវជ្រាវមួយនេះផងដែរ។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

# ជំពូកទី ៤

# លទ្ធស្រាវជ្រាវ

យោងទៅតាមលទ្ធផលនៃការស្រាវជ្រាវ តាមរយៈព័ត៌មានដែលប្រមូលបាន ដែលពាក់ព័ន្ធនឹងប្រធានបទ "**ប្រសិទ្ធភាព នៃការធ្វើកំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិពីឆ្នាំ ២០១៧-២០១៨**" កន្លងមក និងយោងតាមការផ្តល់មតិយោបល់ផ្សេងៗ តាមរយៈការជួបសម្ភាសន៍ លើក្រុមគោលដៅ អំពីបញ្ហាកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងតាមរយៈការផ្តល់អនុសាសន៍លើបណ្តាញសង្គមជាច្រើន យើងឃើញថា វិធានការនៃការធ្វើកំណែទម្រង់លើការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនេះ ពិតជាមានប្រសិទ្ធភាព(ចំណុចខ្លាំង) ល្អគួរឱ្យកោតសរសើរ។ ទន្ទឹមនឹងនេះ ក៏យើងនៅឃើញមានបញ្ហាប្រឈមមួយចំនួនផងដែរ ទៅលើការរៀបចំ និងការអនុវត្ត ដែលមានផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្ស ដែលអ្នកស្រាវជ្រាវកំពុងសិក្សាស្វែងរកក្នុងន័យកែល្អឱ្យកាន់តែមានលក្ខណៈល្អប្រសើរឡើងថែមទៀត។

លទ្ធផល នៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ត្រូវបានបែងចែកជា៥ផ្នែកធំៗគឺ

**១.ការយល់ដឹងអំពីកំណែទម្រង់នៃការប្រឡង**

**២.ដំណើរការ និងការប្រព្រឹត្តទៅនៃការប្រឡង**

**៣.ការពេញចិត្ត និងមិនពេញចិត្តចំពោះកំណែទម្រង់នេះ**

**៤.បញ្ហាប្រឈម និងភាពមិនប្រក្រតីផ្សេងៗ**

**៥.យោបល់បន្ថែម/ដំណោះស្រាយ**

យើងសូមធ្វើការវិភាគ និងសំយោគនូវព័ត៌មាន ដែលយើងប្រមូលបានទាក់ទងទៅនឹងចំណុចទាំង៥ដូចខាងក្រោម៖

❖ **ការយល់ដឹងអំពីកំណែទម្រង់នៃការប្រឡង**

➢ **បរិបទកំណែទម្រង់វិស័យអប់រំ**

នៅបណ្តាប្រទេសជឿនលឿននៅលើសកលលោក ដែលចង់ធ្វើកំណែទម្រង់វិស័យអប់រំ ដំបូងគេច្រើនចាប់ផ្តើមធ្វើកំណែទម្រង់ពីការប្រឡងជាមុនសិន។ តួយ៉ាងដូចជា ប្រទេសសិង្ហបុរី ជប៉ុន និងប្រទេសថៃជាដើម។ ដោយឡែកប្រទេសកម្ពុជាវិញ ក្នុងបរិបទថ្មីនៃការធ្វើសមាហរណកម្មគ្រប់វិស័យឱ្យបោះជំហានចូលក្នុងសាកលភាវូបនីយកម្ម ហើយបាននឹងកំពុងធ្វើកំណែទម្រង់លើគ្រប់វិស័យ ជាពិសេស គឺវិស័យអប់រំបានដើរតួនាទីយ៉ាងសំខាន់ សម្រាប់ធ្វើឱ្យប្រសើរឡើងនូវសន្ទុះសេដ្ឋកិច្ចជាតិ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំរយៈពេល០៥ឆ្នាំ បានដាក់ចេញនូវវិធានការកំណែទម្រង់៨ចំណុច ក្នុងនោះកំណែទម្រង់ការប្រឡងបានដាក់ឱ្យអនុវត្តរយៈពេល០៤ឆ្នាំ កន្លងមកហើយ។

ដើម្បីឱ្យកាន់តែស៊ីជម្រៅថែមទៀត លើការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវសូមបង្ហាញពីការយល់ឃើញរបស់ភាគីពាក់ព័ន្ធតាមរយៈការសម្ភាសកម្រងសំណួរដូចខាងក្រោម៖

## ៤.១.លទ្ធផល នៃការសម្ភាសសិស្សថ្នាក់ទី១២

### ក្រាបទី១៖ បង្ហាញពីភេទអ្នកចូលរួម

**Q1 Gender**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Male | 24 | 30.0 | 30.0 | 30.0 |
| | Female | 56 | 70.0 | 70.0 | 100.0 |
| | Total | 80 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ចំនួនសិស្សថ្នាក់ទី១២ ដែលបានចូលរួមមានសិស្សប្រុសចំនួន២៤នាក់ ស្មើនឹង៣០% និងសិស្សស្រីចំនួន៥៦នាក់ ស្មើនឹង៧០%។

## ក្រាបទី២៖ មុខវិជ្ជាជ្រើសរើសរបស់សិស្ស

**Q2 Subject**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Science | 36 | 45.0 | 45.0 | 45.0 |
| | Social | 44 | 55.0 | 55.0 | 100.0 |
| | Total | 80 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា សិស្សដែលបានចាប់យកមុខវិជ្ជា ថ្នាក់វិទ្យាសាស្ត្រមានចំនួនសិស្ស៣៦នាក់ គឺស្មើនឹង៤៥% និងសិស្សដែលចាប់យកមុខវិជ្ជាថ្នាក់សង្គម មានចំនួន៤៤នាក់ គឺស្មើនឹង៥៥%។ មានន័យថា បច្ចុប្បន្នសិស្សដែលបានចាប់យកថ្នាក់សង្គម គឺមានចំនួនច្រើនជាងថ្នាក់វិទ្យាសាស្ត្រចាប់តាំងពីឆ្នាំសិក្សា២០១៧-២០១៨មក ដោយពួកគេបានយល់ថាថ្នាក់សង្គមងាយស្រួលក្នុងការប្រឡង និងងាយស្រួលជាប់ជាពួកវិទ្យាសាស្ត្រ។

## ក្រាបទី៣៖ ការបង្រៀនរបស់គ្រូតាមកម្មវិធីសិក្សា

**Q3 Teaching Curriculum**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | No | 4 | 5.0 | 5.0 | 5.0 |
| | yes | 76 | 95.0 | 95.0 | 100.0 |
| | Total | 80 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា លោកគ្រូ អ្នកគ្រូពិតជាបានបង្រៀនសិស្សស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ ដែលក្នុងនោះមានសិស្សចំនួន៧៦នាក់ឆ្លើយថា លោកគ្រូ អ្នកគ្រូបានបង្រៀនតាមកម្មវិធីសិក្សារបស់ក្រសួង គឺស្មើនឹង៩៥% តែដោយឡែកមានតែសិស្សប្រមាណជា៥%ប៉ុណ្ណោះ ដែលបានឆ្លើយថា លោកគ្រូ អ្នកគ្រូ មិនបានបង្រៀនតាមកម្មវិធីសិក្សានោះទេ។

## ក្រាបទី៤៖ ការបង្រៀនរបស់គ្រូថ្នាក់ទី១២ បានចប់កម្មវិធីសិក្សាគិតជាភាគរយ(%)

**Q4 Teaching Program**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 60% | 4 | 5.0 | 5.0 | 5.0 |
| | 80% | 22 | 27.5 | 27.5 | 32.5 |
| | 90% | 46 | 57.5 | 57.5 | 90.0 |
| | 100% | 8 | 10.0 | 10.0 | 100.0 |
| | Total | 80 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា លោកគ្រូ អ្នកគ្រូ ដែលបានបង្រៀនចប់កម្មវិធីសិក្សាបានភាគរយត្រឹម៩០% ប៉ុណ្ណោះក្នុងមួយឆ្នាំសិក្សា ដែលមានចំនួនច្រើនជាងគេ។ មូលហេតុ ដោយសារគ្រូមួយចំនួនមិនបានគោរពតាមបំណែងចែកកម្មវិធីសិក្សា និងមួយចំនួនផ្សេងទៀតមានការសុំច្បាប់ឈប់សម្រាកច្រើនជាដើម។

## ក្រាបទី៥៖ គោលវិធី និងវិធីសាស្រ្តបង្រៀនរបស់គ្រូ

**Q5 Teaching Methods**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Teacher center | 5 | 6.3 | 6.3 | 6.3 |
| | Student center | 7 | 8.8 | 8.8 | 15.0 |
| | Together | 68 | 85.0 | 85.0 | 100.0 |
| | Total | 80 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ចំពោះគោលវិធី និងវិធីសាស្រ្តក្នុងការបង្រៀន គឺគ្រូជ្រើសរើសយកគោលវិធីបែបចម្រុះ (គឺគោលវិធីគ្រូមជ្ឈមណ្ឌល និងសិស្សមជ្ឈមណ្ឌលរួមគ្នា) ដែលមានភាគរយប្រើច្រើនជាងគេ គឺរហូតដល់៨៥%ឯណោះ ក្នុងគោលដៅដើម្បីឱ្យសម្រេចវត្ថុបំណងមេរៀនរបស់ពួកគាត់។

## ក្រាបទី៦៖ មុនពេលប្រឡងBacII លោកគ្រូ អ្នកគ្រូបានជួយសិស្ស

**Q6 Before Exam BacII**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Teach get money | 25 | 31.3 | 31.3 | 31.3 |
| | Teach part time no money | 31 | 38.8 | 38.8 | 70.0 |
| | Helping Student | 24 | 30.0 | 30.0 | 100.0 |
| | Total | 80 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា មុនពេលប្រឡងសញ្ញាបត្រមធម្យមសិក្សាទុតិភូមិ លោកគ្រូ អ្នកគ្រូបាន បង្រៀនគួរ បង្រៀនវគ្គបំប៉ន និងបានជួយលើកទឹកចិត្តដល់សិស្សផងដែរ។ ក្នុងគោលបំណងចង់ឱ្យសិស្សបានប្រឡងជាប់ច្រើន និងទទួលបាននិទ្ទេសល្អ។

## ក្រាបទី៧៖ ក្រោយពីបង្រៀន សិស្សទទួលបានចំណេះដឹងពីគ្រូគិតជាភាគរយ(%)

**Q7 Students got Knowledge**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 40% | 2 | 2.5 | 2.5 | 2.5 |
| | 60% | 16 | 20.0 | 20.0 | 22.5 |
| | 80% | 42 | 52.5 | 52.5 | 75.0 |
| | 90% | 18 | 22.5 | 22.5 | 97.5 |
| | 100% | 2 | 2.5 | 2.5 | 100.0 |
| | Total | 80 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ក្រោយពីបង្រៀនមេរៀនចប់ សិស្សទទួលបានចំណេះដឹងពីគ្រូគឺមានប្រមាណជា៨០% មានអត្រាភាគរយខ្ពស់ជាងគេគឺស្មើនឹង៥២.៥០% ពីសិស្ស៤២នាក់ក្នុងចំណោមសិស្ស៨០នាក់។ ក្នុងន័យនេះ គឺបានបង្ហាញថាសិស្សបានយកចិត្តទុកដាក់ក្នុងការរៀនសូត្រនៅក្នុងថ្នាក់ច្រើន។

## ក្រាបទី៨៖ លទ្ធផលសិក្សាប្រចាំឆ្នាំរបស់សិស្សថ្នាក់ទី១២

**Q8 Result end Year**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Medium | 14 | 17.5 | 17.5 | 17.5 |
| | Fair | 51 | 63.8 | 63.8 | 81.3 |
| | Good | 15 | 18.8 | 18.8 | 100.0 |
| | Total | 80 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា លទ្ធផលសិក្សាប្រចាំឆ្នាំរបស់សិស្សថ្នាក់ទី១២ មធ្យមមានចំនួន១៤នាក់ ស្មើនឹង១៧.៥% ល្អបង្គួរមានចំនួន៥១នាក់ ស្មើនឹង៦៣.៨% និងលទ្ធល្អមានចំនួន១៥នាក់ គឺស្មើនឹង១៨.៨%។

## ក្រាបទី៩៖ ការអនុវត្តកិច្ចតែងការបង្រៀនរបស់គ្រូ

**Q9 Lesson Plan**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Very less | 2 | 2.5 | 2.5 | 2.5 |
| | Less | 8 | 10.0 | 10.0 | 12.5 |
| | Sometime | 22 | 27.5 | 27.5 | 40.0 |
| | Often | 21 | 26.3 | 26.3 | 66.3 |
| | Every day | 27 | 33.8 | 33.8 | 100.0 |
| | Total | 80 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ការអនុវត្តកិច្ចតែងការបង្រៀនរបស់គ្រូ ដែលបានប្រើប្រាស់ជាប្រចាំថ្ងៃ(Every day) គឺមានចំនួនភាគរយច្រើនជាងគេគឺស្មើនឹង៣៣.៨% ចំណែកឯគ្រូ ដែលបានប្រើប្រាស់កិច្ចតែងការបង្រៀនតិចតួចបំផុតនោះ គឺស្មើនឹង២.៥% ប៉ុណ្ណោះ។ ដែលនេះបញ្ជាក់ថាលោកគ្រូ អ្នកគ្រូបានយកចិត្តទុកដាក់ទៅលើការប្រើប្រាស់កិច្ចតែងការបង្រៀនរបស់ខ្លួន។

## ក្រាបទី១០៖ ការរៀបចំវិញ្ញាសាប្រឡងឆមាសលើកទី១ និងទី២

**Q10 Test Semester1 and 2**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Not Open Test | 80 | 100.0 | 100.0 | 100.0 |




តាមក្រាបខាងលើបង្ហាញថា ចំពោះការរៀបចំវិញ្ញាសាប្រឡងឆមាសលើកទី១ និងទី២នេះ គឺមានលក្ខណៈជាសម្ងាត់ល្អ ១០០% ដោយមិនមានសិស្សណាម្នាក់ដឹងវិញ្ញាសាមុនបានឡើយ។ ហើយនេះ គឺជាដំណើរការល្អមួយសម្រាប់ឱ្យ សិស្សមានការត្រៀមលក្ខណៈទុកជាមុនក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនាពេលខាងមុខ។

## ក្រាបទី១១៖ ការរៀបចំវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ(ថ្នាក់ជាតិ)

**Q11 Test BacII**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Not Open Test | 80 | 100.0 | 100.0 | 100.0 |




តាមក្រាបខាងលើបង្ហាញថា ការរៀបចំវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ជាតិ) គឺមានលក្ខណៈជាសម្ងាត់ល្អណាស់ ដែលក្រសួងជាអ្នករៀបដោយចំផ្ទាល់ និងមិនមានការយកសំណៅឯកសារចូល និងលួចចម្លងគ្នាក្នុងមណ្ឌលប្រឡងបានឡើយ។ ហើយនេះ គឺជាសញ្ញាមួយ ដែលធ្វើឱ្យសាធារជនមានការជឿទុកចិត្តទៅលើការប្រឡងថ្នាក់ជាតិនេះ។

## ក្រាបទី១២៖ ការរំលឹកមេរៀន និងធ្វើលំហាត់នៅផ្ទះរបស់ប្អូនៗ ថ្នាក់ទី១២

**Q12 Study at Home**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Very less | 1 | 1.3 | 1.3 | 1.3 |
| | Less | 13 | 16.3 | 16.3 | 17.5 |
| | Sometime | 23 | 28.8 | 28.8 | 46.3 |
| | Often | 22 | 27.5 | 27.5 | 73.8 |
| | Every day | 21 | 26.3 | 26.3 | 100.0 |
| | Total | 80 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ចំពោះការរំលឹកមេរៀន និងធ្វើលំហាត់នៅផ្ទះរបស់ប្អូនៗថ្នាក់ទី១២ គឺមានលក្ខណៈល្អច្រើន ហើយមានសិស្សចំនួនតែ១.៣% ប៉ុណ្ណោះ ដែលមិនសូវបាន រំលឹកមេរៀន និងសិក្សាខ្លួនឯងនៅផ្ទះ។ ដូច្នេះ មាតាបិតា ឬអាណាព្យាបាលសិស្សត្រូវយកចិត្តទុកដាក់ និងជំរុញការលើកទឹកចិត្តកូនបន្ថែមទៀត។

## ក្រាបទី១៣៖ អំពីអវត្តមានរបស់សិស្សក្នុងមួយឆ្នាំសិក្សា

**Q13 Attended end year**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Stop more | 11 | 13.8 | 13.8 | 13.8 |
| | Sometime | 17 | 21.3 | 21.3 | 35.0 |
| | Stop less | 46 | 57.5 | 57.5 | 92.5 |
| | Never Stop | 6 | 7.5 | 7.5 | 100.0 |
| | Total | 80 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ចំនួនសិស្សដែលមិនសូវអវត្តមាន មានប្រហាណជា៥៧.៥% សិស្សអវត្តមានច្រើនមានចំនួន១៣.៨% និងសិស្សមិនដែលអវត្តមានសោះមានចំនួន៧.៥% តែប៉ុណ្ណោះ។ ហើយអ្នកស្រាវជ្រាវ បានរកឃើញថាកត្តាដែលនាំឱ្យសិស្សអវត្តមានភាគច្រើន គឺជាសិស្សដែលរៀនខ្សោយ និងខ្វះការយកចិត្តទុកដាក់ពីមាតាបិតា/អាណាព្យាបាលរបស់ពួកគេ។

## ក្រាបទី១៤៖ ការពេញចិត្តលើកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិពីឆ្នាំ ២០១៧ ដល់ ឆ្នាំ២០១៨ កន្លងមក

**Q14 Reform 2017 and 2018**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | don't like | 1 | 1.3 | 1.3 | 1.3 |
| | like less | 2 | 2.5 | 2.5 | 3.8 |
| | like some | 29 | 36.3 | 36.3 | 40.0 |
| | like strong | 39 | 48.8 | 48.8 | 88.8 |
| | like very strong | 9 | 11.3 | 11.3 | 100.0 |
| | Total | 80 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ការពេញចិត្តលើកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិពីឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៨ កន្លងមក មានការពេញចិត្តច្រើនពីសិស្សានុសិស្ស ប៉ុន្តែមានសិស្សប្រមាណជា២.៥% ប៉ុណ្ណោះ ដែលមិនសូវមានការពេញចិត្តលើកំណែទម្រង់នេះ។ មូលហេតុ ដោយសារតែពួកគេរៀនមិនសូវពូកែ និងមានការភ័យខ្លាចខ្លាំងក្នុងការប្រឡងនេះ។

## ៤.២.លទ្ធផល នៃការសម្ភាសលោកគ្រូ អ្នកគ្រូ ដែលបង្រៀនថ្នាក់ទី១២ និងធ្លាប់ជាគណៈកម្មការប្រឡង

### ក្រាបទី១៖ អំពីភេទអ្នកចូលរួមឆ្លើយ

**Q1 Gender**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Male | 21 | 52.5 | 52.5 | 52.5 |
| | Female | 19 | 47.5 | 47.5 | 100.0 |
| | Total | 40 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ក្នុងចំណោមលោកគ្រូ អ្នកគ្រូ ចំនួន៤០នាក់ ក្នុងនោះមានលោកគ្រូចំនួន២១នាក់ គឺស្មើនឹង៥២.៥% និងអ្នកគ្រូចំនួន១៩នាក់ គឺស្មើនឹង៤៧.៥% ដែលបានចូលរួមឆ្លើយសំណួររបស់អ្នកស្រាវជ្រាវ។

## ក្រាបទី២៖ កម្រិតវប្បធម៌របស់គ្រូ

**Q2 Knowledge of Teacher**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | BA | 39 | 97.5 | 97.5 | 97.5 |
| | Master | 1 | 2.5 | 2.5 | 100.0 |
| | Total | 40 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា កម្រិតវប្បធម៌របស់គ្រូ ដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រមាន ចំនួន៣៩នាក់ គឺស្មើនឹង៩៧.៥% រីឯគ្រូដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មានតែ០១នាក់ ប៉ុណ្ណោះ គឺស្មើនឹង២.៥%។ ក្នុងន័យនេះ លោកគ្រូ អ្នកគ្រូភាគច្រើនគួរខំសិក្សាយកថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែមទៀត និងដើម្បីទទួលបានបទ ពិសោធន៍ល្អៗ យកមកបង្រៀនសិស្សឱ្យមានសមត្ថភាពខ្ពស់ផងដែរ។

## ក្រាបទី៣៖ បទពិសោធន៍ក្នុងការបង្រៀន

**Q3 Experience of teaching**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | At less 3 years | 7 | 17.5 | 17.5 | 17.5 |
| | 3 ys to 5 ys | 16 | 40.0 | 40.0 | 57.5 |
| | 5 years up | 17 | 42.5 | 42.5 | 100.0 |
| | Total | 40 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ចំពោះបទពិសោធន៍ក្នុងការបង្រៀន គឺតិចជាង៣ឆ្នាំមានចំនួន០៧នាក់ គឺស្មើនឹង១៧.៥% បង្រៀនបានពី៣ឆ្នាំ ទៅ៥ឆ្នាំមានចំនួន១៦នាក់ គឺស្មើនឹង៤០% និងបង្រៀនបានលើសពី៥ឆ្នាំឡើងទៅ មានចំនួន១៧នាក់គឺស្មើនឹង៤២.៥%។

## ក្រាបទី៤៖ អនុវត្តការបង្រៀនតាមកម្មវិធីសិក្សា ដែរឬទេ?

**Q4 Curriculum**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | yes | 40 | 100.0 | 100.0 | 100.0 |




តាមក្រាបខាងលើបង្ហាញថា លោកគ្រូ អ្នកគ្រូសុទ្ធតែបានបង្រៀនស្របតាមកម្មវិធីសិក្សាទាំងអស់គ្នា គឺស្មើនឹង១០០%។

## ក្រាបទី៥៖ ការបង្រៀនចប់កម្មវិធីសិក្សា គិតជាភាគរយ(%)

**Q5 Curriculum grade12**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 80% | 9 | 22.5 | 22.5 | 22.5 |
| | 90% | 17 | 42.5 | 42.5 | 65.0 |
| | 100% | 14 | 35.0 | 35.0 | 100.0 |
| | Total | 40 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា លោកគ្រូ អ្នកគ្រូ ដែលបានបង្រៀនចប់កម្មវិធីសិក្សាបានចំនួន៩០% ប៉ុណ្ណោះក្នុងមួយឆ្នាំសិក្សា ដែលមានភាគរយខ្ពស់ជាងគេ គឺស្មើនឹង៤២.៥%។ ដូច្នេះ ដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការបង្រៀនកាន់តែខ្ពស់លោកគ្រូ អ្នកគ្រូ គួរតែបង្រៀនឱ្យបានចប់កម្មវិធីសិក្សា១០០% ក្នុងមួយឆ្នាំសិក្សាទើបជាការល្អប្រសើរ។

## ក្រាបទី៦៖ គោលវិធីក្នុងការបង្រៀនរបស់គ្រូ

**Q6 Teaching Method**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Teacher center Approach | 1 | 2.5 | 2.5 | 2.5 |
| | Student Center Approach | 10 | 25.0 | 25.0 | 27.5 |
| | Both | 29 | 72.5 | 72.5 | 100.0 |
| | Total | 40 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ចំពោះគោលវិធីបង្រៀន លោកគ្រូ អ្នកគ្រូបានជ្រើសរើសយកគោលវិធី/វិធិសាស្រ្តបង្រៀនបែបចម្រុះមកប្រើប្រាស់ច្រើនជាងគេ គឺមានរហូតដល់៧២.៥%។ ក្នុងគោលបំណងដើម្បីឆ្លើយតបទៅសមត្ថភាព នៃការយល់ដឹងរបស់សិស្សគ្រប់គ្នា។

## ក្រាបទី៧៖ មុនពេលប្រឡងBacII គ្រូបានជួយដល់សិស្ស

**Q7 Helping to Student**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Teach get money | 9 | 22.5 | 22.5 | 22.5 |
| | Part time Help | 10 | 25.0 | 25.0 | 47.5 |
| | Motivation | 21 | 52.5 | 52.5 | 100.0 |
| | Total | 40 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា មុនពេលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ លោកគ្រូអ្នកគ្រូ បានចូលរួមលើកទឹកចិត្តសិស្សឱ្យមានការខិតខំរៀន ដើម្បីទទួលបានជោគជ័យក្នុងពេលប្រឡងនាពេលខាងមុខ។

## ក្រាបទី៨៖ លទ្ធផលដែលសិស្សទទួលបានពីការបង្រៀនរបស់គ្រូ គិតជាភាគរយ(%)

**Q8 Result of teaching**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 60% | 12 | 30.0 | 30.0 | 30.0 |
| | 80% | 23 | 57.5 | 57.5 | 87.5 |
| | 90% | 5 | 12.5 | 12.5 | 100.0 |
| | Total | 40 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា បន្ទាប់ពីការបង្រៀនរបស់គ្រូចប់ លទ្ធផលដែលសិស្សទទួលបានចំណេះដឹងពីមេរៀនបានប្រមាណជា៨០% ដែលមានអត្រាភាគរយច្រើនជាងគេ គឺស្មើនឹង ៥៧.៥%។ ដូច្នេះ លោកគ្រូ អ្នកគ្រូ គួរខិតខំប្រឹងបន្ថែមទៀត និងព្យាយាមជួយសិស្ស ដែលរៀនយឺតឱ្យខំប្រឹងប្រែងរៀនសូត្របន្ថែមទៀតផងដែរ។

## ក្រាបទី៩៖ លទ្ធផលសិស្សប្រឡងមធ្យមសិក្សាទុតិយភូមិ ២០១៧-២០១៨

**Q9 Test Result (2017-2018)**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Medium | 8 | 20.0 | 20.0 | 20.0 |
| | faire | 25 | 62.5 | 62.5 | 82.5 |
| | good | 6 | 15.0 | 15.0 | 97.5 |
| | Excellent | 1 | 2.5 | 2.5 | 100.0 |
| | Total | 40 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ចំពោះលទ្ធផលសិស្សពេលប្រឡងមធ្យមសិក្សាទុតិយភូមិពីឆ្នាំ២០១៧-២០១៨ គឺសិស្សភាគច្រើនទទួលបានល្អបង្គួរ(ស្មើនឹងនិទ្ទេសD) ដែលមានភាគរយខ្ពស់ជាងគេមានប្រមាណជា ៦២.៥%។

# ក្រាបទី១០៖ ការអនុវត្តលើកិច្ចតែការបង្រៀនរបស់គ្រូ

**Q10 Lesson Plan**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | A little | 3 | 7.5 | 7.5 | 7.5 |
| | Sometime | 16 | 40.0 | 40.0 | 47.5 |
| | Often | 18 | 45.0 | 45.0 | 92.5 |
| | Every day | 3 | 7.5 | 7.5 | 100.0 |
| | Total | 40 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ចំពោះការអនុវត្តលើកិច្ចតែការបង្រៀនរបស់គ្រូ គឺមានលក្ខណៈល្អប្រសើរច្រើន ដោយលោកគ្រូ អ្នកគ្រូភាគច្រើនបាអនុវត្តលើកិច្ចតែងការបង្រៀនរបស់ខ្លួនជារឿយៗផងដែរ។ ម្យ៉ាងវិញទៀត លោកគ្រូ អ្នកគ្រូ គួរធ្វើបច្ចុប្បន្នភាពលើកិច្ចតែងការបង្រៀនរបស់ខ្លួន ដើម្បីមានចំណេះដឹងថ្មីៗ យកមកបង្ហាត់បង្រៀនដល់សិស្ស។

## ក្រាបទី១១៖ ការរៀបចំវិញ្ញាសាប្រឡងមធ្យមសិក្សាទុតិយភូមិ

**Q11 Exam Document**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Open docs | 1 | 2.5 | 2.5 | 2.5 |
| | Standard Docs | 23 | 57.5 | 57.5 | 60.0 |
| | Secret Docs | 16 | 40.0 | 40.0 | 100.0 |
| | Total | 40 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា ការរៀបចំវិញ្ញាសាប្រឡងមធ្យមសិក្សាទុតិយភូមិ(ថ្នាក់ជាតិ) មានលក្ខណៈជាសម្ងាត់ល្អ ដែលមានចំនួនភាគរយខ្ពស់ជាងគេរហូតដល់៥៧.៥% ដោយមិនមានអ្នកណាមួយដឹងវិញ្ញាសាមុនបានឡើយ។

## ៤.៣.លទ្ធផល នៃការសម្ភាសនាយក ឬគណៈគ្រប់គ្រងសាលា

### ក្រាបទី១៖ អំពីភេទអ្នកចូលរួមឆ្លើយ

**Q1 Gender**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Male | 12 | 100.0 | 100.0 | 100.0 |




តាមក្រាបខាងលើបង្ហាញថា ចំនួននាយក/នាយករង ទាំង០៩វិទ្យាល័យនៅក្នុងខេត្តកំពត ដែលអ្នកស្រាវជ្រាវបានធ្វើការសម្ភាសន៍ មានចំនួន១២នាក់នោះ គឺប្រុសទាំងអស់។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា ថ្នាក់ដឹកនាំភាគច្រើន គឺសុទ្ធសឹងជាបុរស ដែលនេះគឺជាគម្លាតយេនឌ័រមួយដ៏គួរឱ្យកត់សម្គាល់ផងដែរ។

## ក្រាបទី២៖ អំពីកម្រិតវប្បធម៌ នាយក/នាយករង ទាំង០៩វិទ្យាល័យ

**Q2 Knowledge**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | BA | 8 | 66.7 | 66.7 | 66.7 |
| | Master | 4 | 33.3 | 33.3 | 100.0 |
| | Total | 12 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា លោកនាយក/នាយករង ដែលមានកម្រិតវប្បធម៌បញ្ចប់ថ្នាក់ Master មានចំនួន០៤នាក់ ស្មើនឹង ៣៣.៣% និងលោកនាយក/នាយករង មានកម្រិតវប្បធម៌បញ្ចប់ថ្នាក់បរិញ្ញាបត្រមានចំនួន០៨នាក់ គឺស្មើនឹង ៦៦.៧%។

## ក្រាបទី៣៖ អំពីបទពិសោធន៍ក្នុងការដឹកនាំ និងគ្រប់គ្រង

**Q3 Leader Experience**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 3-5 y | 5 | 41.7 | 41.7 | 41.7 |
| | 5 up | 7 | 58.3 | 58.3 | 100.0 |
| | Total | 12 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា លោកនាយក/នាយករង ដែលមានបទពិសោធន៍ក្នុងការដឹកនាំ និងគ្រប់គ្រង ចន្លោះពី៣ទៅ៥ឆ្នាំមានចំនួន០៥នាក់ ស្មើនឹង៤១.៧% និងលោកនាយក/នាយករង ដែលមានបទពិសោធន៍ក្នុងការដឹកនាំ និងគ្រប់គ្រងពី៥ឆ្នាំឡើងទៅមានចំនួន០៧នាក់ ស្មើនឹង ៥៨.៣%។

## ក្រាបទី៤៖ បានត្រួតពិនិត្យការងាររដ្ឋបាលថ្នាក់រៀនរបស់បុគ្គលិក

**Q4 Control Staff**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Sometime | 3 | 25.0 | 25.0 | 25.0 |
| | Often | 6 | 50.0 | 50.0 | 75.0 |
| | every day | 3 | 25.0 | 25.0 | 100.0 |
| | Total | 12 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា លោកនាយក/នាយករងចំនួន០៣នាក់ ដែលបានពិនិត្យលើការងាររដ្ឋថ្នាក់របស់បុគ្គលិករបស់ខ្លួនម្តងម្កាលគឺស្មើនឹង២៥% រីឯលោកនាយក/នាយករងចំនួន០៦នាក់ បានពិនិត្យមើលការងាររដ្ឋថ្នាក់របស់បុគ្គលិករបស់ខ្លួនជារឿយៗ ស្មើនឹង៥០% និងលោកនាយក/នាយករងចំនួន០៣នាក់ ដែលបានពិនិត្យលើការងាររដ្ឋថ្នាក់របស់បុគ្គលិករបស់ខ្លួន ជាប្រចាំ គឺស្មើនឹង២៥%។ ដូច្នេះ លោកនាយក/នាយករងទាំងអស់គួរមានការពង្រឹងឡើងវិញលើការពិនិត្យ និងតាមដានការងាររដ្ឋបាលថ្នាក់បុគ្គលិករបស់ខ្លួនឱ្យបានជាប់ជាប្រចាំទើបជាការល្អ។

## ក្រាបទី៥៖ លោកគ្រូ អ្នកគ្រូថ្នាក់ទី១២ បង្រៀនចប់កម្មវិធីសិក្សាគិតជាភាគរយ(%)

**Q5 Staff teach curriculum G12**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 80% | 1 | 8.3 | 8.3 | 8.3 |
| | 90% | 6 | 50.0 | 50.0 | 58.3 |
| | 100% | 5 | 41.7 | 41.7 | 100.0 |
| | Total | 12 | 100.0 | 100.0 | |




តាមក្រាបខាងលើបង្ហាញថា លោកនាយក/នាយករង ចំនួន០៥នាក់ប៉ុណ្ណោះ ដែលបានឆ្លើយថា បុគ្គលិករបស់គាត់បានបង្រៀនចប់កម្មវិធីសិក្សាថ្នាក់ទី១២ចប់បាន១០០% គឺស្មើនឹង ៤១.៧%ប៉ុណ្ណោះ ទាំងនេះហើយជាចំណុចខ្វះខាត និងត្រូវតែកែលម្អឡើងវិញ នៅលោកគ្រូ អ្នកគ្រូមួយចំនួនទៀត ដែលមិនបានបង្រៀនបានចប់កម្មវិធីសិក្សា គួរធ្វើយ៉ាងណាត្រូវអនុវត្តឱ្យបានចប់១០០%គ្រប់គ្នា ព្រោះថាថ្នាក់ទី១២ ជាឆ្នាំដែលត្រូវប្រឡងទទួលសញ្ញាបត្រផង។

## ក្រាបទី៦៖ ប្រសិទ្ធភាព នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ(២០១៧-២០១៨)

**Q6 Like about Exam 2014-2018**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
